ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រជាតិ
## ស្តីពី
## ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម
## ឆ្នាំ២០២៦-២០៣០

ខែកក្កដា ឆ្នាំ២០២៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រជាតិ

# ស្ដីពី

# ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម

# ឆ្នាំ២០២៦-២០៣០

ខែកក្កដា ឆ្នាំ២០២៦

# បុព្វកថា

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាសម្រេចបាននូវសុខសន្តិភាពពេញបរិបូរណ៍ បូរណភាពទឹកដី និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧% មុនមានវិបត្តិនៃជំងឺកូវីដ-១៩។ បន្ទាប់ពីវិបត្តិ សេដ្ឋកិច្ចកម្ពុជាបានងាកទៅរកគន្លងសក្តានុពលវិញជាសន្សឹមៗ ដោយក្នុងឆ្នាំ២០២៥ កំណើន ផ.ស.ស. របស់កម្ពុជា ស្ថិតក្នុងរង្វង់ ៥,៣%។ សមិទ្ធផលគួរជាទីមោទនៈនេះសម្រេចបានតាមរយៈការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាល ដែលបានអនុវត្តនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីកែទម្រង់សំខាន់ៗ ប្រកបដោយស្មារតីបុរេសកម្ម និងការទទួលខុសត្រូវ សំដៅអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិទាំងមូល។ ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញ និងអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានគូសបញ្ជាក់ពីសារៈសំខាន់នៃការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម (ស.ម.ត.ម.) និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅក្នុងបញ្ចកោណទី៣ ស្តីពីការជំរុញអភិវឌ្ឍវិស័យឯកជន និងការងារ។

ស្របតាមបរិការណ៍នេះ ស.ម.ត.ម. ត្រូវបានចាត់ទុកថាជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ដែលបានរួមចំណែកផ្តល់ការងារដល់ប្រជាជនប្រមាណ ៧០% ព្រមទាំងជាប្រភពមិនចេះរីងស្ងួតសម្រាប់ពិពិធកម្មសេដ្ឋកិច្ច ការបង្កើតតម្លៃបន្ថែម និងនវានុវត្តន៍។ យ៉ាងណាមិញ ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ជាសកល ការបន្សល់ទុកស្លាកស្នាមពីវិបត្តិនៃជំងឺកូវីដ-១៩ ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងសង្គ្រាមពាណិជ្ជកម្មបាននិងកំពុងផ្តល់ផលជះអវិជ្ជមានដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមទាំងក្នុងតំបន់ និងសកលលោក ដោយក្នុងនោះ កម្ពុជាបានទទួលកម្មវិបាកដោយផ្ទាល់ និងប្រយោល ជារួម និងជាពិសេសចំពោះ ស.ម.ត.ម.។ លើសពីនេះ ជម្លោះព្រំដែនបានដាក់បន្ទុកបន្ថែមដល់កម្ពុជាក៏ពិតមែន ប៉ុន្តែក៏បានផ្តល់នូវកាលានុវត្តភាពដល់ការពង្រឹងភាពធន់នៃសេដ្ឋកិច្ច តាមរយៈការជំរុញផលិតកម្មក្នុងស្រុក និងការលើកកម្ពស់សមត្ថភាពសហគ្រាសក្នុងស្រុក ក្នុងការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃក្នុងប្រទេស តំបន់ និងសកលលោក។ ទោះជាយ៉ាងណាក៏ដោយ ការជំរុញអភិវឌ្ឍ ស.ម.ត.ម. ចាំបាច់ទាមទារនូវការដោះស្រាយបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលរួមមាន ភាពស្មុគស្មាញនៃក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីចុះបញ្ជី និងបំពេញអនុលោមភាពផ្សេងៗ ភាពមានកម្រិតនៃសមត្ថភាពប្រកួតប្រជែងទាំងក្នុងទិដ្ឋភាពថ្លៃដើម និងទិដ្ឋភាពស្តង់ដាគុណភាព កង្វះការផ្សារភ្ជាប់ ស.ម.ត.ម.ទៅនឹងខ្សែច្រវាក់តម្លៃក្នុងប្រទេស តំបន់ និងសកល ក៏ដូចជាកង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រទាំងផ្នែករឹង និងផ្នែកទន់។

ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ "**យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០**" ក្នុងចក្ខុវិស័យ "***ជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម (ស.ម.ត.ម.) កម្ពុជា ឱ្យក្លាយជាមូលដ្ឋានគ្រឹះ និងជាកម្លាំងចលករដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចជាតិ ដែលនឹងនាំមកនូវវឌ្ឍនភាពសង្គម និងវិបុលភាពសម្រាប់ប្រជាជាតិកម្ពុជា***" ។

យុទ្ធសាស្ត្រនេះនឹងផ្ដោតជាចម្បងលើសសរស្ដម្ភយុទ្ធសាស្ត្រចំនួន ៤ រួមមាន៖ ១)- ការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់ ២)- ការលើកកម្ពស់សមត្ថភាពផលិតកម្ម សេវាកម្ម និងការចាប់យកបច្ចេកវិទ្យា និងនវានុវត្តន៍ ៣)- ការបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារជាតិ និងអន្តរជាតិ និង ៤)- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថាយុទ្ធសាស្ត្រជាតិនេះនឹងក្លាយជាផែនទីបង្ហាញផ្លូវដ៏មានប្រសិទ្ធភាពក្នុងការជំរុញ ស.ម.ត.ម. ប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសម្ដែងនូវការវាយតម្លៃខ្ពស់ ចំពោះក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានចូលរួមរៀបចំយុទ្ធសាស្ត្រជាតិនេះ រហូតសម្រេចបានជោគជ័យ។ ខ្ញុំសង្ឃឹមថា គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ទាំងនៅរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ នឹងចូលរួមអនុវត្តយុទ្ធសាស្ត្រនេះ ប្រកបដោយស្មារតីបុរេសកម្ម និងសហថាមពល ស្របតាមអភិក្រម «**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**»។

ថ្ងៃ សុក្រ ១១ រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២៦

**នាយករដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា * នាយករដ្ឋមន្ត្រី *

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ក.ក.ន. | ក្រសួងកិច្ចការនារី |
| ក.ក.ប. | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ប. | ក្រសួងបរិស្ថាន |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ក.ផ. | ក្រសួងផែនការ |
| ក.ព.ណ. | ក្រសួងពាណិជ្ជកម្ម |
| ក.រ.ថ. | ក្រសួងរ៉ែ និងថាមពល |
| ក.វ.ស. | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ក.ស.ក. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.ស.ដ. | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ក.អ.ជ. | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ក.ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ក.អ.យ.ក | ក្រសួងអប់រំ យុវជន និងកីឡា |
| គ.រ.ម. | ទីស្តីការគណៈរដ្ឋមន្ត្រី |
| គ.ស.ធ.ឱ. | គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល |
| គ.ស.ម.ត.ម. | គណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម |
| គ.ស.ហ. | គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ធ.ជ.ក. | ធនាគារជាតិនៃកម្ពុជា |
| ធ.ស.ក | ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា |
| ធ.អ.ជ. | ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ម.ធ.ត. | មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" នៃ ក.ស.ហ.វ. |
| ម.អ.ជ. | មូលនិធិអភិវឌ្ឍន៍ជំនាញ នៃ ក.ស.ហ.វ. |
| ស.ធ.ក. | សាជីវកម្មធានាឥណទានកម្ពុជា |
| ស.ត.ម. | សហគ្រាសធុនតូច និងមធ្យម |
| ស.ម.ត.ម. | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| អ.គ.រ. | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃ ក.ស.ហ.វ. |
| អ.ប.វ. | អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| អ.ព.ដ. | អគ្គនាយកដ្ឋានពន្ធដារ នៃ ក.ស.ហ.វ. |

# មាតិកា


បុព្វកថា ........ i
បញ្ជីអក្សរកាត់ ........ iii
មាតិកា ........ iv
**ផ្នែកទី១ សេចក្តីផ្តើម** ........ 1
១.១. ស្ថានភាពសេដ្ឋកិច្ចជារួម ........ 1
១.២. ទស្សនាទាននៃការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ........ 2
**ផ្នែកទី២ ស្ថានភាពរួមនៃសហគ្រាសធុនមីក្រូ តូច និងមធ្យមកម្ពុជា** ........ 5
២.១. និយមន័យបច្ចុប្បន្ននៃសហគ្រាសធុនមីក្រូ តូច និងមធ្យម ........ 5
២.២. ស្ថានភាពបច្ចុប្បន្ននៃសហគ្រាសធុនមីក្រូ តូច និងមធ្យម ........ 6
២.៣. ការគាំទ្ររបស់រាជរដ្ឋាភិបាលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ........ 8
២.៤. បញ្ហាប្រឈម របស់សហគ្រាសធុនមីក្រូ តូច និងមធ្យម ........ 10
**ផ្នែកទី៣ ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រជាតិ** ........ 13
៣.១. ចក្ខុវិស័យ ........ 13
៣.២. គោលបំណង និងគោលដៅ ........ 13
៣.៣. វិសាលភាព និងអភិក្រមនៃយុទ្ធសាស្ត្រ ........ 14
**ផ្នែកទី៤ យុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សហគ្រាសធុនមីក្រូ តូច និងមធ្យម** ........ 16
៤.១. ក្របខ័ណ្ឌយុទ្ធសាស្ត្រ ........ 16
    ៤.១.១. ការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់ ........ 17
    ៤.១.២. ការលើកកម្ពស់សមត្ថភាពផលិតកម្ម សេវាកម្ម និងការចាប់យកបច្ចេកវិទ្យា និងនវានុវត្តន៍ ........ 19
    ៤.១.៣. ការបង្កើនសមត្ថភាពប្រកួតប្រជែង ក្នុងទីផ្សារជាតិ និងអន្តរជាតិ ........ 21
    ៤.១.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ........ 24
៤.២. ផែនការសកម្មភាពគន្លឹះ ........ 27
**ផ្នែកទី៥ ការគ្រប់គ្រងហានិភ័យ** ........ 28

**ផ្នែកទី៦ យន្តការស្ថាប័ន និងការតាមដាននិងវាយតម្លៃ** ..... 30
៦.១. ការរៀបចំក្របខ័ណ្ឌស្ថាប័ន និងយន្តការសម្របសម្រួល ..... 30
៦.១.១. គណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍ គ.ស.ម.ត.ម. ..... 30
៦.១.២. លេខាធិការដ្ឋាន នៃ គ.ស.ម.ត.ម. ..... 31
៦.១.៣. ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត ..... 32
៦.១.៤. ធនធានសម្រាប់អនុវត្តយុទ្ធសាស្ត្រ ..... 33
៦.២. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិ ..... 33
៦.២.១. យន្តការតាមដាន និងត្រួតពិនិត្យ ..... 33
៦.២.២. យន្តការវាយតម្លៃ ..... 35
**ផ្នែកទី៧ សេចក្តីសន្និដ្ឋាន** ..... 37
**ឧបសម្ព័ន្ធទី១៖ តារាងផែនការសកម្មភាពគន្លឹះសម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០** ..... 38

# ផ្នែកទី១
# សេចក្តីផ្តើម

## ១.១. ស្ថានភាពសេដ្ឋកិច្ចជារួម

សេដ្ឋកិច្ចសកល និងក្នុងតំបន់ នៅបន្តហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ដែលអាចបន្ទច់បង្អាក់ដល់សន្ទុះនៃកំណើនសេដ្ឋកិច្ច ទាំងរយៈពេលខ្លី និងមធ្យមខាងមុខ។ ជាក់ស្តែង សេដ្ឋកិច្ចសកល មានស្ថានភាពកាន់តែផុយស្រួយ និងស្រួចស្រាល់នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបណ្តាលមកពីភាពតានតឹងពាណិជ្ជកម្មសកលកាន់តែខ្លាំងឡើង ជាពិសេសពន្ធគយបដិការថ្មី ដែលប្រកាសដោយសហរដ្ឋអាម៉េរិក និងវិធានការឆ្លើយតបពីដៃគូពាណិជ្ជកម្មសំខាន់ៗ។ ការវិវត្តទាំងនេះ បានបង្កើតភាពមិនច្បាស់លាស់នៅក្នុងខ្សែប្រវាក់ផ្គត់ផ្គង់សកល និងធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់វិនិយោគិន និងជញ្ជីងពាណិជ្ជកម្ម។ ទន្ទឹមនេះ ហានិភ័យភូមិសាស្ត្រនយោបាយដូចជាជម្លោះនៅមជ្ឈិមបូព៌ា និងការប្រែប្រួលទីផ្សារហិរញ្ញវត្ថុក៏បង្កការគំរាមកំហែងបន្ថែមទៀតដល់ស្ថិរភាពពិភពលោក រំហូរមូលធន និងទីផ្សារទំនិញផងដែរ។

ជាមួយគ្នានេះ កម្ពុជា ក៏រងនូវផលប៉ះពាល់ពីកត្តាខាងក្រៅ ទាំងលើទិដ្ឋភាពពាណិជ្ជកម្មអន្តរជាតិ និងភូមិសាស្ត្រនយោបាយ ដែលបានគម្រាមកំហែងដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ក្នុងដំណើរកំពុងវិលត្រលប់ទៅរកគន្លងសក្តានុពលវិញជាសន្សឹមៗ នៅក្រោយពហុវិបត្តិនាពេលកន្លងទៅ។ ទោះបីជាយ៉ាងនេះក្តី កម្ពុជាអាចសម្រេចបានសមិទ្ធផលសេដ្ឋកិច្ចជាវិជ្ជមាន ដោយសាររាជរដ្ឋាភិបាលបានដាក់ចេញ និងជំរុញអនុវត្តយ៉ាងសកម្ម និងទាន់ពេល នូវគោលនយោបាយត្រឹមត្រូវ មុតស្រួច និងចំទិសដៅ នៅតាមវិស័យសំខាន់ៗជាអាទិភាព មានជាអាទិ៍៖ ការពង្រឹងអភិបាលកិច្ច ការទ្រទ្រង់កំណើន និងធ្វើទំនើបកម្មសេដ្ឋកិច្ច ការបង្កើតការងារទាំងគុណភាព និងបរិមាណ ការលើកស្ទួយវិស័យឯកជន និងសហគ្រិនភាព ការកសាងមូលធនមនុស្ស ការលើកស្ទួយសេវាគាំពារសង្គមនិងសុខុមាលភាពប្រជាជន ការពង្រឹងចីរភាពបរិស្ថាននិងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ការជំរុញបរិវត្តកម្មឌីជីថលទាំងក្នុងសង្គម និងសេដ្ឋកិច្ច ការស្តារនូវវិស័យជាចន្ទល់នៃកំណើនដែលមានស្រាប់ ក៏ដូចជាការលើកកម្ពស់វិស័យសក្តានុពលថ្មីមួយចំនួនទៀត។ កម្ពុជានឹងបន្តពុះពារជម្នះនូវបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពតំបន់និងសកល រួមមាន ការបន្តប្រឈមមុខខាងភូមិសាស្ត្រនយោបាយដែលកាន់តែស្រួចស្រាល់ ការបែកខ្ញែកនៃសេដ្ឋកិច្ចសកលដែលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការនិងពាណិជ្ជកម្មអន្តរជាតិ ការងើបមកវិញនៃនិន្នាការឯកតោភាគីនិយម ភាពមិនច្បាស់លាស់នៃទស្សនវិស័យនៃកំណើនសេដ្ឋកិច្ចនៃបណ្តាប្រទេស និងតំបន់ ដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា និងការប្រែប្រួលអាកាសធាតុជាដើម។

ក្នុងបរិការណ៍នេះ ការជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដើម្បីឈានទៅរកគន្លងសក្តានុពល និងឈានទៅសម្រេចបានចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា ទាមទារឱ្យមានការគិតគូរដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធរបស់សេដ្ឋកិច្ចកម្ពុជា ជាពិសេសបញ្ហានៃចន្លោះកណ្តាលក្នុងសេដ្ឋកិច្ច ( Missing Middle ) ដែលបណ្តាលឱ្យសេដ្ឋកិច្ចកម្ពុជា មិនអាចទាញយកប្រយោជន៍បានជាអតិបរមាពីរំហូរទុនវិនិយោគ

ពីក្រៅប្រទេសបានពេញលេញ ខណៈដែលមូលដ្ឋានសហគ្រាសក្នុងស្រុក នៅមានភាពទន់ខ្សោយ និងខ្វះលទ្ធភាពប្រកួតប្រជែង។ ក្នុងន័យនេះ ទិសដៅអភិវឌ្ឍសេដ្ឋកិច្ចនាដំណាក់កាលបន្ទាប់ ចាំបាច់ត្រូវផ្តោតលើការពង្រឹងភាពធន់ និងភាពរឹងមាំនៃមូលដ្ឋានគ្រឹះសេដ្ឋកិច្ចកម្ពុជា ជាពិសេសក្នុងវិស័យឯកជន ដោយផ្តោតលើការជំរុញអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម (ស.ម.ត.ម.) និងការជំរុញការផ្សារភ្ជាប់ជាមួយខ្សែច្រវាក់តម្លៃក្នុងប្រទេស តំបន់ និងសកល។

## ១.២. ទស្សនាទាននៃការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម

រាជរដ្ឋាភិបាលនីតិកាលទី៦ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងវិធានការគាំទ្រនានា ដើម្បីអភិវឌ្ឍវិស័យ ស.ម.ត.ម. ដែលជាសក្ខីភាពនៃការផ្តោតការយកចិត្តទុកដាក់ និងផ្តល់នូវសារៈសំខាន់ចំពោះវិស័យនេះ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានចាត់វិធានការដើម្បីសម្រួលដល់កំណើន ស.ម.ត.ម. និងលើកកម្ពស់បរិយាកាសធុរកិច្ចផងដែរ រួមមានកំណែទម្រង់អភិបាលកិច្ច ការលើកកម្ពស់ការអប់រំ ការលើកទឹកចិត្តផ្នែកពន្ធ អភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក និងការពង្រឹងលទ្ធភាពទទួលបានហិរញ្ញប្បទាន។ ទោះបីបាននិងកំពុងប្រឈមនឹងស្ថានភាពដូចបានរៀបរាប់ខាងដើមក្តី ក៏ ស.ម.ត.ម. ទាំងអស់បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិត ការផ្គត់ផ្គង់ និងការផ្តល់សេវា ហើយក៏កំពុងខិតខំអភិវឌ្ឍ និងវិវត្តខ្លួនឱ្យឆ្លើយតបទៅនឹងនិន្នាការថ្មីៗ ជាពិសេសគឺបត់បែនការប្រែប្រួលផ្នែកលក្ខខណ្ឌតម្រូវរបស់ទីផ្សារ លក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងការវិវត្តដ៏លឿននៃបច្ចេកវិទ្យាផងដែរ។

យ៉ាងណាមិញ ស.ម.ត.ម. នៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធមួយចំនួន ដែលរួមមានសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធមានទំហំធំ ភាពមានកម្រិតនៃសមត្ថភាពផលិតកម្មក្នុងស្រុក និងការប្រកួតប្រជែងជាមួយទំនិញនាំចូលពីបរទេស កង្វះកម្លាំងពលកម្មមានជំនាញ និងភាពមានកម្រិតក្នុងការទទួលបានហិរញ្ញប្បទានដែលមានលក្ខខណ្ឌសមប្រទាន ក៏ដូចជាកង្វះការផ្សារភ្ជាប់ជាមួយខ្សែច្រវាក់តម្លៃក្នុងប្រទេស តំបន់ និងសកល។

រាជរដ្ឋាភិបាលនីតិកាលទី៧ ក្រោមការដឹកនាំប្រកបដោយថាមភាពរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបន្តយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាប្រឈមនានារបស់ ស.ម.ត.ម. ជាពិសេសតាមរយៈ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានកំណត់ការលើកស្ទួយ ស.ម.ត.ម. និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាយុទ្ធសាស្ត្រគន្លឹះមួយក្នុងបញ្ចកោណទី ៣ ស្តីពីការជំរុញអភិវឌ្ឍវិស័យឯកជន និងការងារ។ ក្នុងនោះ រាជរដ្ឋាភិបាលបានប្តេជ្ញាយ៉ាងមោះមុត ក្នុងការបន្តអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានាតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្ម និង ស.ម.ត.ម. ដោយផ្តោតសំខាន់លើការអភិវឌ្ឍសហគ្រិនភាព វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ រាជរដ្ឋាភិបាលបាននិងកំពុង

ធ្វើពិពិធកម្មទីផ្សារទាំងក្នុងតំបន់ និងសកល តាមរយៈការជំរុញ និងលើកកម្ពស់ ស.ម.ត.ម. ឱ្យក្លាយជាខ្សែប្រវាក់ផលិតកម្ម និងសេវាកម្មដែលផ្តល់តម្លៃបន្ថែមខ្ពស់ និងប្រែក្លាយជាឧស្សាហកម្មប្រតិគមន៍ (Backward Linkage Industry) ការជំរុញការរៀបចំបណ្តុំសហគ្រាសធុនតូច និងមធ្យម (SMEs Cluster) ឱ្យកាន់តែច្រើន ការជំរុញឱ្យ ស.ម.ត.ម. ចាប់យកឧស្សាហកម្មបៃតង និងមានសុខដុមនីយកម្មជាមួយសង្គម បរិស្ថាន (Green MSMEs & ESG) និងការប្រែក្លាយផលិតផលរបស់ ស.ម.ត.ម. ឱ្យកាន់តែមានគុណភាព សោភ័ណភាព ស្តង់ដា ការប្រកួតប្រជែងខ្ពស់ និងការជំរុញការកសាង និងការពង្រឹងប្រព័ន្ធអេកូឡូស៊ី ស.ម.ត.ម.។ ប្រព័ន្ធអេកូឡូស៊ីដែលមានភាពប្រទាក់ក្រឡាគ្នា និងគាំទ្រគ្នាទៅវិញទៅមកប្រកបដោយសហថាមពលនេះ កំពុងបង្កើតនូវទំនុកចិត្ត និងភាពទាក់ទាញដល់ការបង្កើន និងការពង្រីកវិនិយោគលើ ស.ម.ត.ម. ឱ្យមានចីរភាព និងជាឆ្អឹងខ្នងដ៏រឹងមាំនៃសេដ្ឋកិច្ចជាតិ។

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពប្រកួតប្រជែង ភាពរឹងមាំ និងភាពធន់ទៅនឹងវិបត្តិ តាមរយៈការកែលម្អបរិយាកាសធុរកិច្ច ការពង្រឹងសមត្ថភាព និងកែលម្អការផ្តល់សេវាសាធារណៈ ការបន្តធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងខ្សែប្រវាក់ផ្គត់ផ្គង់ក្នុងស្រុក សំដៅជំរុញការតភ្ជាប់ទៅនឹងខ្សែប្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និងសកល ការចាប់យកសកម្មភាពផលិតកម្មនិងសេវាកម្មដែលបង្កើតតម្លៃបន្ថែមខ្ពស់ ការបង្កើតការងារសម្រាប់កម្លាំងពលកម្មដែលមានជំនាញ និងការពង្រីកមូលដ្ឋានសេដ្ឋកិច្ចជាតិ ឱ្យកាន់តែទូលំទូលាយជាដើម។

ឈរលើទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តដាក់ចេញនូវគោលនយោបាយ ឬយុទ្ធសាស្ត្រ ក៏ដូចជាវិធានការអន្តរាគមន៍នានាសម្រាប់ ស.ម.ត.ម. ដោយផ្តោតលើការធានាបានភាពធន់ និងរឹងមាំរបស់ ស.ម.ត.ម. ការលើកកម្ពស់ភាពប្រកួតប្រជែង និងពង្រឹងសមត្ថភាពផលិតកម្ម និងការជំរុញការតភ្ជាប់របស់ ស.ម.ត.ម. ទៅនឹងខ្សែប្រវាក់តម្លៃក្នុងប្រទេស តំបន់ និងសកល សំដៅបង្កើនការចូលរួមក្នុងកំណើនសេដ្ឋកិច្ច ដើម្បីឈានទៅសម្រេចចក្ខុវិស័យជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ក៏ដូចជាត្រៀមខ្លួនឱ្យបានរឹងមាំ សម្រាប់ការចាកចេញពីចំណាត់ក្រុមប្រទេសដែលមានការអភិវឌ្ឍតិចតួច នៅឆ្នាំ២០២៩ ខាងមុខ។

ក្នុងន័យនេះ ក្រសួង ស្ថាប័នទទួលបន្ទុក ស.ម.ត.ម. ទាំងអស់ ត្រូវសហការ និងចូលរួមលើកកម្ពស់ ស.ម.ត.ម. តាមរយៈការពង្រឹងសមត្ថភាពសហគ្រាស ការកំណត់សហគ្រាសសក្តានុពល ការអភិវឌ្ឍផលិតផលនិងសេវាកម្មថ្មីៗ ការពង្រីកទីផ្សារក្នុងស្រុក ការតភ្ជាប់ខ្សែប្រវាក់តម្លៃ និងការតភ្ជាប់បណ្តាញផលិតកម្មនិងសេវាកម្មក្នុងស្រុក និងតំបន់ ។ បន្ថែមលើនេះ ក្រសួង ស្ថាប័នទទួលបន្ទុក ស.ម.ត.ម. ក៏ត្រូវកែសម្រួលអភិក្រម និងពង្រឹងអភិបាលកិច្ច ដោយធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈឱ្យមានតម្លាភាព ប្រក្រតីភាព ភាពជឿទុកចិត្តបាន កាត់បន្ថយបន្ទុកអនុលោមភាពដែលមិនចាំបាច់ និងពង្រឹងប្រព័ន្ធផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ដើម្បីកែលម្អបរិយាកាសធុរកិច្ច និងពង្រឹងភាពប្រកួតប្រជែងរបស់ ស.ម.ត.ម.។ ទន្ទឹមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវពង្រឹងយន្តការគ្រប់គ្រង និងតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការអភិវឌ្ឍ ស.ម.ត.ម. ដែលនឹងផ្តល់នូវព័ត៌មានគន្លឹះសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំកែសម្រួល និងដាក់ចេញនូវវិធានការគោលនយោបាយបន្តបន្ទាប់ ស្របតាមការចាំបាច់របស់រាជរដ្ឋាភិបាល។

ជាការពិត វិស័យឯកជន ជាពិសេសសហគ្រិនក្នុងស្រុក មានតួនាទីគន្លឹះក្នុងការចូលរួមទ្រទ្រង់

និងពង្រឹងប្រព័ន្ធអេកូឡូស៊ីនេះ តាមរយៈការក្តាប់យកឱកាស និងបន្តរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាព វិនិយោគលើការពង្រឹងស្តង់ដា និងគុណភាពនៃផលិតផល និងសេវាកម្មរបស់ខ្លួន បង្កើនផលិតភាពតាមរយៈការបន្តបណ្តុះបណ្តាលបុគ្គលិកនិយោជិត និងផ្តល់នូវរបបសន្តិសុខសង្គម ក៏ដូចជាការចាប់យកបច្ចេកវិទ្យា និងទំនើបកម្មខ្សែច្រវាក់ផលិតកម្ម សេវាកម្មរបស់ខ្លួន។ អនុលោមភាពនៃច្បាប់ និងបទដ្ឋានគតិយុត្ត និងការកាន់បញ្ជិកាគណនេយ្យ ក៏ត្រូវបានលើកតម្កើង និងចាត់ទុកជាការវិនិយោគដែលនឹងផ្តល់ផលប្រយោជន៍ត្រលប់មកវិញដល់វិស័យឯកជន ជាជាងបន្ទុកនៃការធ្វើធុរកិច្ចផងដែរ។

ជារួម ការដាក់ចេញនូវទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញអភិវឌ្ឍ ស.ម.ត.ម. នឹងត្រូវការចាំបាច់នូវការចូលរួមប្រកបដោយភាពបុរេសកម្មពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពង្រឹងសមត្ថភាព កែលម្អបរិស្ថានធុរកិច្ច និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ ក៏ដូចជាការចូលរួមពីវិស័យឯកជន ជាពិសេស ស.ម.ត.ម. ផ្ទាល់ ក្នុងការចាប់យកកាលានុវត្តភាពថ្មីៗ និងការចូលរួមបំពេញអនុលោមភាពតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងន័យនេះ ផ្អែកតាមបរិការណ៍ខាងលើ ក៏ដូចជាបញ្ហាប្រឈមជារចនាសម្ព័ន្ធនានាដែលរាំងស្ទះដល់ការរីកលូតលាស់របស់ ស.ម.ត.ម. រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការរៀបចំ និងដាក់ឱ្យអនុវត្ត "**យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០**" សំដៅជំរុញការអភិវឌ្ឍ ស.ម.ត.ម. ឱ្យមានភាពធន់ និងរឹងមាំនៅកម្ពុជា និងលើកកម្ពស់ការចូលរួមរបស់ ស.ម.ត.ម. ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

# ផ្នែកទី២
# ស្ថានភាពរួមនៃសហគ្រាសធុនមីក្រូ តូច និងមធ្យមកម្ពុជា

## ២.១. និយមន័យបច្ចុប្បន្ននៃសហគ្រាសធុនមីក្រូ តូច និងមធ្យម

ក្នុងបរិបទអន្តរជាតិ ស.ម.ត.ម. គឺជាសហគ្រាសដែលមិនមែនជាក្រុមហ៊ុនបុត្រសម្ព័ន្ធ និងជាសហគ្រាសឯករាជ្យ ដោយមានចំនួនបុគ្គលិកតិចជាងក្នុងកម្រិតណាមួយ។ ជាទូទៅ សហគ្រាសធុនតូចត្រូវបានកំណត់ចំនួនបុគ្គលិកពី ១០ ទៅ ៥០នាក់ ហើយសហគ្រាសធុនមធ្យមមានបុគ្គលិកពី ៥០ ទៅ ២០០នាក់ និងអាចយោងទៅលើទំហំនៃផលរបរ ឬទ្រព្យសកម្ម ទៅតាមបរិបទប្រទេសនីមួយៗផងដែរ។

សម្រាប់កម្ពុជា ស្របតាមការកំណត់របស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០២១ និយមន័យសហគ្រាសធុនតូច និងមធ្យមត្រូវបានកំណត់ដោយប្រើប្រាស់លក្ខខណ្ឌចំនួនបុគ្គលិក និងកម្រិតផលរបរ ឬកម្រិតទ្រព្យសកម្ម។ ការកំណត់និយមន័យនេះត្រូវបានបែងចែកជា ៣ ក្រុមតាមសកម្មភាពសេដ្ឋកិច្ច រួមមានកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម និងពាណិជ្ជកម្ម។ ការកំណត់និយមន័យសហគ្រាសធុនតូច និងមធ្យម មានលម្អិតក្នុងតារាងខាងក្រោម៖

តារាងទី ១៖ និយមន័យសហគ្រាសធុនតូច និងមធ្យមនាពេលបច្ចុប្បន្ន

| និយមន័យ | | ចំនួនបុគ្គលិក | ផលរបរ (ដុល្លារអាមេរិក) | ទ្រព្យសកម្ម (ដុល្លារអាមេរិក) |
|---|---|---|---|---|
| កសិកម្ម | តូច | 5 – 49 | 62,250 – 250,000 | 50,000 – 250,000 |
| | មធ្យម | 50 – 199 | 250,001 – 1,000,000 | 250,001 – 500,000 |
| ឧស្សាហកម្ម | តូច | 5 – 49 | 62,500 – 400,000 | 50,000 – 500,000 |
| | មធ្យម | 50 - 199 | 400,001 – 2,000,000 | 500,001 – 1,000,000 |
| សេវាកម្ម និងពាណិជ្ជកម្ម | តូច | 5 – 49 | 62,500 – 250,000 | 50,000 – 250,000 |
| | មធ្យម | 50 – 99 | 250,001 – 1,500,000 | 250,001 – 500,000 |

*ប្រភព៖ លិខិតលេខ ៣៦ សជណ.ហធ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី*

ដោយឡែក និយមន័យសហគ្រាសធុនមីក្រូ មិនទាន់ត្រូវបានកំណត់បានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយនៅឡើយ។ ជាក់ស្តែង ការកំណត់និយមន័យសហគ្រាសធុនតូច និងមធ្យម ក្នុងតារាងទី១ កាលពីឆ្នាំ២០២១ ក៏មិនទាន់បានកំណត់លក្ខណៈរបស់សហគ្រាសធុនមីក្រូ។ យ៉ាងណាមិញ ក្របខ័ណ្ឌអភិវឌ្ឍន៍

សហគ្រាសធុនតូច និងមធ្យម កាលពីឆ្នាំ២០០៥ ធ្លាប់បានកំណត់និយមន័យសហគ្រាសធុនមីក្រូ ដោយមានចំនួនបុគ្គលិកតិចជាង១០នាក់និងទំហំទ្រព្យសកម្មតិចជាង៥ម៉ឺនដុល្លារអាមេរិក។សរុបជារួមនិយមន័យ ស.ម.ត.ម. នៅមិនទាន់បានកំណត់គ្រប់ជ្រុងជ្រោយ និងមានភាពជាក់ស្តែងនិយម ដែលឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃការវិវត្តសង្គម-សេដ្ឋកិច្ច។

## ២.២ ស្ថានភាពបច្ចុប្បន្ននៃសហគ្រាសធុនមីក្រូ តូច និងមធ្យម

ស.ម.ត.ម.បានដើរតួនាទីដ៏សំខាន់ក្នុងការជំរុញពិពិធកម្មសេដ្ឋកិច្ច ជានាភាពម្ចាស់ការនៃខ្សែច្រវាក់ផ្គត់ផ្គង់ បង្កើតការងារ ជំនាញឯកទេសនិងបច្ចេកទេស សហគ្រិនភាព និងការច្នៃប្រឌិតបច្ចេកវិទ្យាថ្មីៗ ដើម្បីជានាបាននូវការទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយជវភាពនិងអធិបតេយ្យភាព។ស.ម.ត.ម.ភាគច្រើនធ្វើប្រតិបត្តិការជាសហគ្រាសកែច្នៃម្ហូបអាហារ សហគ្រាសក្នុងវិស័យទេសចរណ៍ កសិ-ឧស្សាហកម្ម និងសហគ្រាសកម្មន្តសាលកែច្នៃផលិតផលប្រើប្រាស់ទូទៅ។ កំណើននៃចំនួន ស.ម.ត.ម. ការពង្រឹងគុណភាពផលិតផល និងភាពអនុលោមជាមួយទីផ្សារតំបន់ និងអន្តរជាតិ បានក្លាយជាសក្តានុពលសេដ្ឋកិច្ចដ៏ធំរបស់កម្ពុជានាពេលបច្ចុប្បន្ន និងតទៅអនាគត។ ក្នុងន័យនេះ រាជរដ្ឋាភិបាល ទាំងក្នុងនីតិកាលមុនៗ និងសម្រាប់នីតិកាលទី ៧ នេះ បានទទួលស្គាល់ថា សហគ្រាសក្នុងស្រុក ទាំងធុនមីក្រូ តូច និងមធ្យម គឺជាឆ្អឹងខ្នងដ៏រឹងមាំនៃសង្គម-សេដ្ឋកិច្ចជាតិ ដែលបាននិងកំពុងរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កើតការងារ និងមុខរបរ ការបង្កើនប្រាក់ចំណូល ការកាត់បន្ថយភាពក្រីក្រ និងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់។

បច្ចុប្បន្ននេះ ស.ម.ត.ម. មានប្រមាណ ៩០% នៃមូលដ្ឋានផលិតកម្ម អាជីវកម្មសរុប បានផ្តល់ប្រមាណ ៧០% នៃកម្លាំងពលកម្មសរុប និងរួមចំណែកប្រមាណ ៥០% នៃផលិតផលក្នុងស្រុកសរុបនៅទូទាំងពិភពលោក។ នៅក្នុងក្របខ័ណ្ឌអាស៊ាន មានចំនួនសហគ្រាសសរុបប្រមាណ ៧០លានមូលដ្ឋាន (ចន្លោះពី ៩៧,២% ទៅ ៩៩,៩%) និងរួមចំណែកក្នុងរង្វង់ ៤៤,៨% នៃផលិតផលក្នុងស្រុកសរុប។

រូបភាពទី១៖ ទិន្នន័យពាក់ព័ន្ធ ស.ម.ត.ម.

| | |
|---|---|
| អង្គភាពសេដ្ឋកិច្ច៖ | ៧៥៣ ៦៧០ មូលដ្ឋាន |
| កម្លាំងពលកម្មសរុប៖ | ២ ៩៨០ ៥៦៩ នាក់ (ស្ត្រី ១ ៨៤១ ៣៦២ នាក់) |
| ការចូលរួមក្នុង ផ.ស.ស.៖ | ស្មើនឹង ៦៣% (ដោយមិនរាប់ចូលវិស័យកសិកម្ម) |
| ការផ្តល់ការងារ៖ | លើសពី ៧០% (ដោយមិនរាប់ចូលវិស័យកសិកម្ម) |
| ការចូលរួមខ្លាំងនៅវិស័យសេវាកម្ម៖ | ប្រហែល ៩៣% |

*ប្រភព៖ វិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ ឆ្នាំ២០២២*

យោងតាមរបាយការណ៍ថ្នាក់ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ចនៅឆ្នាំ២០២២ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កម្ពុជាមានអង្គភាពសេដ្ឋកិច្ច (ឬជា ស.ម.ត.ម.) ចំនួន ៧៥៣ ៦៧០ មូលដ្ឋាន មានកម្លាំងពលកម្មសរុប ២ ៩៨០ ៥៦៩ នាក់ ក្នុងនោះស្ត្រីមាន ១ ៨៤១ ៣៦២ នាក់។ ទន្ទឹមនេះ ស.ម.ត.ម. បានចូលរួមក្នុងផលិតផលក្នុងស្រុកសរុបស្មើ ៦៣% និងផ្តល់ការងារលើសពី ៧០% (ដោយមិនរាប់បញ្ចូលវិស័យកសិកម្ម)។ ដោយឡែក អ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធមានចំនួនជិត ៦,២លាននាក់ ដែលក្នុងនោះក៏មានសហគ្រាសធុនមីក្រូផងដែរ។

រូបភាពទី២៖ ទិន្នន័យពាក់ព័ន្ធសហគ្រាសធុនតូច និងមធ្យម

**ទិន្នន័យ ស.ត.ម.**

| | |
|---|---|
| ស.ត.ម. ចុះបញ្ជីនៅឆ្នាំ២០២៣ | ៦០ ៥០៣ មូលដ្ឋាន |
| កម្លាំងពលកម្ម | ៦៧៨ ៧៤០ នាក់ |
| ចំណូលពីការនាំចេញ | ស្មើរនឹង ១០% នៃការនាំចេញសរុប |
| ទំហំនៃការនាំចេញ | ២ ៩៥៥ ៣៧៥ ០៩៨,៦៣ ស្មើនឹង ១៦,៥៣% នៃការនាំចេញសរុប |
| ស.ត.ម. ដែលនាំចេញ | ០,៧៦% នៃ ស.ត.ម. សរុប |
| ផលិតកម្មរបស់ ស.ត.ម. | ស្មើនឹង ២៦,៣១% នៃនាំចេញសរុប ក្នុងនោះមានផលិតផលសំខាន់ៗដូចជា៖ សម្លៀកបំពាក់ គ្រឿងអលង្ការ ផលិតផលឈើ គ្រឿងសង្ហារឹម |

*ប្រភព៖ ក្រសួងពាណិជ្ជកម្ម (តួលេខ៨ខែនៃឆ្នាំ២០២៥)*

## ២.៣. ការគាំទ្ររបស់រាជរដ្ឋាភិបាលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម

ផ្អែកលើមូលដ្ឋានខាងលើនេះហើយ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ នៃរដ្ឋសភា បានបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍសហគ្រាសក្នុងស្រុកគ្រប់ប្រភេទ តាមរយៈការកសាងប្រព័ន្ធអេកូឡូស៊ីរស់រវើក និងគ្រប់ជ្រុងជ្រោយ ដើម្បីផ្តល់ការគាំទ្រលើទិដ្ឋភាពសំខាន់ៗដូចខាងក្រោម៖

**ទី១.** ការរៀបចំ និងដាក់ឱ្យអនុវត្ត «**យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨**» ដែលជា **កម្មវិធីគោលនយោបាយអាទិភាពមួយ** ក្នុងចំណោម **កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦** នៃ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល នៅដើមនីតិកាលកន្លងមក។ យុទ្ធសាស្ត្រជាតិនេះមានចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរីកធំធាត់ និងមានលទ្ធភាពឈានចូលសេដ្ឋកិច្ចក្នុងប្រព័ន្ធ ហើយអាចក្លាយជាកម្លាំងចលករដ៏សំខាន់ ក្នុងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ទៅនឹងវិបត្តិ។

**ទី២.** **ការកែលម្អបរិយាកាសធុរកិច្ច** តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវវិធានការកែទម្រង់មុតស្រួច និងចំទិសដៅ ដើម្បីដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងបង្កើតបរិយាកាសអំណោយផល ជាពិសេសការកាត់បន្ថយបន្ទុកចំណាយរបស់ ស.ម.ត.ម. ក្នុងស្រុក។ ជាក់ស្តែង រាជរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ បានបង្កើតយន្តការធ្វើអធិការកិច្ចរួម និងបានរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការចុះបញ្ជីអាជីវកម្ម និងការស្នើសុំអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្ម តាមប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ផ្អែកលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដែលហៅកាត់ជាភាសាអង់គ្លេសថា "CamDX" ស្របតាម "**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ២០២៥-២០២៨**"។

**ទី៣.** **ការជំរុញ និងការលើកកម្ពស់សហគ្រិនភាព និងការចាប់យកបច្ចេកវិទ្យាឌីជីថល** តាមរយៈការបង្កើត **មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី «តេជោ» មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព** និង **សហគ្រិនខ្មែរ**។ ទីភ្នាក់ងារទាំងនេះបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនៅកម្ពុជា តាមរយៈការផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដល់ធុរកិច្ចថ្មី និង ស.ម.ត.ម. ដែលមានសក្តានុពលខ្ពស់ ការបង្កើនផលិតភាព ការបង្កើតសេវា ឬផលិតផលថ្មី និងការផ្គូផ្គងអាជីវកម្ម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តនូវ "**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ឆ្នាំ២០២៦-២០៣០**" ដើម្បីបន្តអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីកម្ពុជា ឱ្យមានបរិយាកាសអំណោយផល និងមានការតភ្ជាប់ជាប្រព័ន្ធ។

**ទី៤.** **ការគាំទ្រដល់ការអភិវឌ្ឍជំនាញ** តាមរយៈការបណ្តុះបណ្តាលផ្ទាល់ និងសហហិរញ្ញប្បទាន។ កាលពីដើមឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្ពោធជាផ្លូវការនូវ **មូលនិធិអភិវឌ្ឍន៍ជំនាញ** (ម.អ.ជ.) ដែលមានបេសកកម្ម ជំរុញភាពជាដៃគូជិតស្និទ្ធរវាងវិស័យឯកជន និងគ្រឹះស្ថានបណ្តុះបណ្តាល តាមរយៈការផ្តល់ហិរញ្ញប្បទានដល់ការបណ្តុះបណ្តាលជំនាញសម្រាប់ការត្រៀមចូលទីផ្សារការងារ ការលើកកម្ពស់ជំនាញ និងការផ្លាស់ប្តូរជំនាញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យឯកជន រួមទាំងសហគ្រាសក្នុងស្រុកធុនមីក្រូ តូច និងមធ្យម ផងដែរ។

**ទី៥. ការលើកកម្ពស់ស្តង់ដាផលិតផល** តាមរយៈការពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ រួមមានការផ្តល់សេវានៃការធ្វើតេស្តពិសោធន៍ ការធ្វើស្តង់ដារូបនីយកម្ម ការវាយតម្លៃអនុលោមភាពផលិតផលឬសេវាកម្ម ការធ្វើព្យាសកម្ម និងត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ និងការវាយតម្លៃទទួលស្គាល់ ដើម្បីលើកកម្ពស់សហគ្រាសគ្រប់ប្រភេទ កាត់បន្ថយនូវរបាំងបច្ចេកទេស និងជំរុញការធ្វើពាណិជ្ជកម្មរបស់វិស័យឯកជន។

**ទី៦. ការលើកកម្ពស់ការទទួលបានហិរញ្ញប្បទាន និងឥណទាន** តាមរយៈការបង្កើត **ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា (ធ.ស.ក.) ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.) សាជីវកម្មធានាឥណទានកម្ពុជា (ស.ធ.ក.) ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ ខេមបូឌា** និង **សហគ្រិនខ្មែរ**។ ដើម្បីសម្រេចគោលដៅនេះ ក្នុងពេលកន្លងទៅ រាជរដ្ឋាភិបាលបានប្រឹងប្រែងបង្កើនថវិកាជូន **ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា** និង **ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម** ជាបន្តបន្ទាប់។

**ទី៧. ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ ស.ម.ត.ម.** តាមរយៈការផ្តល់អត្ថប្រយោជន៍ពន្ធលើការចំណាយដែលអាចកាត់កងបានបន្ថែម សម្រាប់វិស័យអាទិភាពចំនួន ៦ រួមមាន កសិ-ឧស្សាហកម្ម ផលិតនិងកែច្នៃម្ហូបអាហារ កម្មន្តសាលផលិតទំនិញប្រើប្រាស់ក្នុងស្រុកនិងទេសចរណ៍ ការផ្គត់ផ្គង់ផ្នែក ឬគ្រឿងបង្គុំឱ្យកម្មន្តសាលផ្សេងៗ ការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងសហគ្រាសនៅក្នុងតំបន់ប្រមូលផ្តុំ ស.ម.ត.ម.។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានអនុវត្តយន្តការលើកទឹកចិត្តពន្ធដារសម្រាប់ការចុះបញ្ជីពន្ធដោយស្ម័គ្រចិត្ត តាមអនុក្រឹត្យលេខ ១៧ និងអនុក្រឹត្យលេខ ២៧២ ដើម្បីជំរុញឱ្យសហគ្រាសក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឈានចូលប្រព័ន្ធផ្លូវការ។ វិធានការទាំងនេះមានគោលបំណងបង្កើតប្រព័ន្ធពន្ធប្រកបដោយតម្លាភាព និងយុត្តិធម៌ ខណៈដែលការគាំទ្រដល់ ស.ម.ត.ម. ក្នុងវិស័យលក់ដុំ-លក់រាយ សេវាស្នាក់នៅ និងអាហារ សិប្បកម្ម និងសហគមន៍កសិកម្ម ដើម្បីមានលទ្ធភាពអភិវឌ្ឍ និងរីកចម្រើនប្រកបដោយចីរភាព។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានផ្តល់ការលើកទឹកចិត្តផ្នែកគយចំពោះ ស.ម.ត.ម. ដើម្បីអាចទទួលបានការលើកលែងពន្ធគយលើការនាំចូលឧបករណ៍ផលិតកម្ម ឧបករណ៍សំណង់ និងវត្ថុធាតុដើម/ធាតុចូលផលិតកម្មផ្សេងទៀត រួមមាន៖ សហគ្រាសផលិត និងផ្គត់ផ្គង់ទឹកស្អាត សហគ្រាសបម្រើឱ្យការនាំចេញ សហគ្រាសជាប្រភេទឧស្សាហកម្មគាំទ្រ សហគ្រាសបម្រើតម្រូវការក្នុងស្រុក និងការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន។

**ទី៨. ការគាំទ្រការអភិវឌ្ឍ និងការលើកកម្ពស់ផលិតផលក្នុងស្រុក** តាមរយៈការជំរុញចលនាគាំទ្រផលិតផលក្នុងស្រុកឱ្យបានផុសផុល និងការគាំទ្រការអភិវឌ្ឍផលិតកម្មក្នុងស្រុក ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែង និងបំពេញតម្រូវការទីផ្សារជាតិ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ក្នុងការចូលរួមគាំទ្រផលិតផលក្នុងស្រុក តាមរយៈការអំពាវនាវ និងការផ្សព្វផ្សាយ រួមមានការកំណត់រៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលជាតិខ្មែរ (ថ្ងៃទី៩ ខែមេសា) ទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម នៅថ្ងៃទី២៧ ខែមិថុនា ជារៀងរាល់ឆ្នាំ ការសម្របសម្រួលចងក្រងបណ្តុំអ្នកផលិត និងការកំណត់ផលិតផលសក្តានុពល សម្រាប់ដាក់បញ្ចូលក្នុងយន្តការភូមិមួយផលិតផលមួយជាដើម។

## ២.៤. បញ្ហាប្រឈមរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម

ទោះបីរាជរដ្ឋាភិបាលបានផ្តល់ការគាំទ្រជាគោលនយោបាយច្រើនហើយក្តី ក៏ ស.ម.ត.ម. នៅតែបន្តជួបបញ្ហាប្រឈមទាំងក្នុងដំណាក់កាលចាប់ផ្តើម ដំណាក់កាលប្រតិបត្តិការ ដំណាក់កាលចូលទៅកាន់ទីផ្សារ និងដំណាក់កាលបិទអាជីវកម្ម ដោយសារកត្តាចម្បងដូចខាងក្រោម៖

### ក. បរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់

- និយមន័យសហគ្រាសធុនតូច និងមធ្យមត្រូវបានអនុវត្តតាមរយៈ សជណ លេខ៣៦ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល។ ការអនុវត្តនិយមន័យនេះ នៅមិនទាន់មានសង្គតិភាព ខណៈដែលនិយមន័យនេះទៀតសោត នៅមិនទាន់មានភាពសមស្រប ដែលឆ្លុះបញ្ចាំងនឹងតថភាពជាក់ស្តែង និងពុំទាន់បានរាប់បញ្ចូលសហគ្រាសធុនមីក្រូនៅឡើយ ជាពិសេសលើការកំណត់កម្រិតផលរបរ ដើម្បីកំណត់អត្តសញ្ញាណ និងទំហំសហគ្រាស។
- ក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ការស្នើសុំអាជ្ញាបណ្ណ និងការបំពេញកាតព្វកិច្ចអនុលោមភាព នៅមានភាពស្មុគស្មាញ ត្រួតគ្នារវាងក្រសួង ស្ថាប័ន និងដាក់បន្ទុកច្រើនទៅដល់សហគ្រាសធុនតូច និងមធ្យម ដែលមិនទាន់បង្កើតបរិយាកាសអំណោយផលសម្រាប់សហគ្រាសធុនតូច និងមធ្យម អាចលូតលាស់ឆាប់រហ័សបាន។
- កង្វះយន្តការតាមដាន និងកំណត់ស្ថានភាពសហគ្រាសជាប្រចាំ ដែលប៉ះពាល់ដល់លទ្ធភាពក្នុងការកំណត់បាននូវស្ថានភាពជាក់ស្តែងនៃសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។
- សហគ្រាសប្រមាណ ៨៦,៦% ពុំទាន់បានចុះបញ្ជីផ្លូវការ ដោយប្រតិបត្តិការនៅក្រៅប្រព័ន្ធ ជាហេតុនាំឱ្យមានការលំបាកក្នុងការជំរុញអនុវត្តគោលនយោបាយ និងផ្តល់ការគាំពារពីរាជរដ្ឋាភិបាល ជាពិសេសការផ្តល់ និងទទួលបានព័ត៌មានពាក់ព័ន្ធនឹងការលើកទឹកចិត្ត ការផ្ទេរបច្ចេកវិទ្យា និងការអភិវឌ្ឍបច្ចេកទេស។
- ការយល់ដឹងអំពីការបិទក្រុមហ៊ុន ឬបញ្ឈប់អាជីវកម្មនៅមានកម្រិត។
- យន្តការលើកទឹកចិត្តផ្នែកពន្ធដារ និងផ្នែកគយ និងការអនុគ្រោះដល់ ស.ម.ត.ម. ដែលបានដាក់ឱ្យអនុវត្តនាពេលកន្លងមក នៅមិនទាន់អនុវត្តបានទូលំទូលាយ និងនៅមានកម្រិតនៅឡើយ ខណៈដែល ស.ម.ត.ម. ភាគច្រើននៅបន្តនៅក្រៅប្រព័ន្ធ។

### ខ. សមត្ថភាពប្រតិបត្តិការ ផលិតកម្ម សេវាកម្ម និងបច្ចេកវិទ្យា និងនវានុវត្តន៍

- ផលិតកម្មភាគច្រើននៅប្រើប្រាស់បច្ចេកវិទ្យាតាមបែបប្រពៃណី ហើយផលិតផលិតផលមានលក្ខណៈប្រហាក់ប្រហែលគ្នា ធ្វើឱ្យមានការប្រកួតប្រជែងខ្លាំង និងមិនអាចបំពេញតម្រូវការទីផ្សារបានល្អ។
- ថ្លៃដើមផលិតកម្មរបស់ ស.ម.ត.ម. មានកម្រិតខ្ពស់ ដោយសារសម្ភារ បរិក្ខារ និងគ្រឿងម៉ាស៊ីនបម្រើដល់ផលិតកម្ម និងវត្ថុធាតុដើម នៅពឹងផ្អែកលើការនាំចូលពីបរទេស ដែលការនាំចូលនៅ

ជួបប្រទះបញ្ហានីតិវិធីស្មុគស្មាញ និងចំណាយខ្ពស់ បើធៀបនឹងរោងចក្រធុនធំ ជាពិសេសការវិនិយោគផ្ទាល់ពីបរទេស ដែលជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ខណៈដែលថ្លៃអគ្គិសនី ការដឹកជញ្ជូន និងភស្តុភារកម្ម ក៏មានតម្លៃខ្ពស់។

- ទុនវិនិយោគ កម្លាំងពលកម្មជំនាញ ជំនាញបច្ចេកទេស និងគ្រប់គ្រង ការគាំទ្រដល់ការបង្កើតធុរកិច្ចថ្មី ការប្រើបច្ចេកទេសឌីជីថល និងការទទួលបានព័ត៌មានពីទីផ្សារ នៅមានកម្រិត។
- គុណភាព និងស្តង់ដាផលិតកម្មរបស់ ស.ម.ត.ម. នៅមានកម្រិតក្នុងការប្រកួតប្រជែងជាមួយទំនិញនាំចូល ខណៈដែលហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិគាំទ្រដល់ការចាប់យក និងអភិវឌ្ឍស្តង់ដាជាតិ នៅមានភាពខ្វះខាត រួមមានកង្វះមន្ទីរពិសោធន៍ និងសមត្ថភាពតេស្តគុណភាពផលិតផល។

## គ. សមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារ

- វំហូរនៃទំនិញ និងសេវាកម្មមួយចំនួនពីក្រៅប្រទេស មានតម្លៃទាបជាងផលិតផល និងសេវាកម្មរបស់ ស.ម.ត.ម. ដែលនាំឱ្យមានការលំបាកក្នុងការចូលទៅកាន់ទីផ្សារធំៗក្នុងស្រុក។
- ភាពមិនស្មើគ្នានៃតម្រូវការអនុលោមភាពរវាងផលិតផលក្នុងស្រុក និងផលិតផលនាំចូល។
- លទ្ធភាពក្នុងការបំពេញស្តង់ដា និងអនុលោមភាពសម្រាប់ការនាំចេញផលិតផលទៅក្រៅប្រទេសនៅមានកម្រិត។
- យន្តការកំណត់ទម្រង់ និងលក្ខខណ្ឌនៃការរៀបចំសំបកវេចខ្ចប់ និងស្លាកសញ្ញាផលិតផល (Packaging & labeling) នៅមិនទាន់បានគ្រប់ជ្រុងជ្រោយ និងល្អប្រសើរ។
- ការតភ្ជាប់ជាមួយឧស្សាហកម្មអនុគមន៍ និងប្រតិគមន៍ និងប្រព័ន្ធអេកូឡូស៊ីនៅមានកម្រិត ទាំងលើទិដ្ឋភាពនៃភាពខ្វះចន្លោះនូវការទទួលបានព័ត៌មាន (Information Asymmetry) រវាង ស.ម.ត.ម. និងអ្នកទិញ និងសមត្ថភាពក្នុងការបំពេញលក្ខខណ្ឌនៃតម្រូវការរបស់អ្នកទិញ។
- សហគ្រាសធុនតូចនិងមធ្យមភាគច្រើនមិនទាន់អាចឆ្លើយតបនឹងស្តង់ដាគុណភាពនិងអនាម័យអន្តរជាតិដូចជា Good Manufacturing Practice (GMP), Good Hygiene Practice (GHP), International Organization for Standardization (ISO) និង Hazard Analysis and Critical Control Point (HACCP) ដែលជាលក្ខខណ្ឌតម្រូវរបស់អ្នកទិញខ្នាតធំ។
- ការគ្រប់គ្រងគុណភាពផលិតផលនៅមានភាពខ្វះខាត។

## ឃ. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ផ្នែករឹង និងទន់

- ហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ (National Quality Infrastructure - NQI) ដែលរួមមានមន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលមាត្រាសាស្ត្រនៅមានកម្រិត ទាំងលើទិដ្ឋភាពសម្ភារ ឧបករណ៍ បរិក្ខារ និងជំនាញបច្ចេកទេស ក៏ដូចជាធនធានមនុស្ស។

- មិនទាន់មានបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធ សម្រាប់ការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម។
- ការលំបាកក្នុងការទទួលបានប្រាក់កម្ចី ឬឥណទានពីធនាគារ ដោយសារតែខ្វះទ្រព្យធានា និងគ្មានប្រវត្តិហិរញ្ញវត្ថុច្បាស់លាស់ កង្វះការយល់ដឹងអំពីការងារឌីជីថល និងការគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធវាយតម្លៃហានិភ័យឥណទានសម្រាប់ ស.ម.ត.ម. មិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងកង្វះផលិតផលហិរញ្ញវត្ថុបែបច្នៃប្រឌិត ដូចជា៖ Venture Capital, Angel Investment និង Green Finance ដែលអាចជួយជំរុញការវិនិយោគថ្មីៗ។
- ស.ត.ម. មិនទាន់បានអនុវត្តទូលំទូលាយនូវរបាយការណ៍ហិរញ្ញវត្ថុដែលមានស្តង់ដាររួមដែលតម្រូវដោយធនាគារសម្រាប់ការវាយតម្លៃហានិភ័យ។
- ភាពមានកម្រិតនៃចំណេះដឹងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រាក់ចំណូល។

# ផ្នែកទី៣
# ក្របខ័ណ្ឌរួមនៃយុទ្ធសាស្រ្តជាតិ

## ៣.១. ចក្ខុវិស័យ

យុទ្ធសាស្ត្រជាតិនេះមានចក្ខុវិស័យ ជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យមកម្ពុជាឱ្យក្លាយជាមូលដ្ឋានគ្រឹះ និងជាកម្លាំងចលករដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចជាតិ ដែលនឹងនាំមកនូវវឌ្ឍនភាពសង្គម និងវិបុលភាពសម្រាប់ប្រជាជាតិកម្ពុជា។

## ៣.២. គោលបំណង និងគោលដៅ

យុទ្ធសាស្ត្រជាតិនេះមានគោលបំណងលើកកម្ពស់សមត្ថភាព និងភាពធន់របស់ ស.ម.ត.ម. ឱ្យក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសេដ្ឋកិច្ចជាតិ តាមរយៈការកសាងមូលដ្ឋានរឹងមាំសម្រាប់ ស.ម.ត.ម. ក្នុងការអភិវឌ្ឍខ្លួនប្រកបដោយភាពធន់ និងចីរភាព ការពង្រឹងសមត្ថភាពផលិតកម្មបំពេញតម្រូវការក្នុងស្រុក និងលទ្ធភាពនាំចេញ និងការពង្រឹងការផ្សារភ្ជាប់រវាង ស.ម.ត.ម. ទៅនឹងខ្សែច្រវាក់តម្លៃក្នុងស្រុក តំបន់ និងសកល។

ដើម្បីសម្រេចបានចក្ខុវិស័យ និងគោលបំណងខាងលើ យុទ្ធសាស្ត្រជាតិនេះ មានគោលដៅសំខាន់ៗ ចំនួន ៣ ដូចខាងក្រោម៖

១. **ការកសាងមូលដ្ឋានរឹងមាំសម្រាប់ ស.ម.ត.ម. ក្នុងការអភិវឌ្ឍខ្លួនប្រកបដោយភាពធន់ និងចីរភាព** ដែលឆ្លុះបញ្ចាំងតាមរយៈអត្រាកំណើននៃការចុះបញ្ជីអាជីវកម្មផ្លូវការ របស់ ស.ម.ត.ម.។

២. **ការពង្រឹងសមត្ថភាពផលិតកម្មបំពេញតម្រូវការក្នុងស្រុក និងលទ្ធភាពនាំចេញរបស់ ស.ម.ត.ម.។** ការសម្រេចបានគោលដៅនេះ អាចឆ្លុះបញ្ចាំងតាមរយៈការសម្រេចឱ្យបានត្រឹមឆ្នាំ២០៣០ នូវ៖ ១)- ចំណែកនៃសមត្ថភាពផ្គត់ផ្គង់តម្រូវការក្នុងស្រុកយ៉ាងតិច ៥០% នៃតម្រូវការសរុបសម្រាប់មុខទំនិញយុទ្ធសាស្ត្រ ១៥ មុខដែលកំណត់ដោយរាជរដ្ឋាភិបាល និង ២)- ចំនួនមុខទំនិញដែល ស.ម.ត.ម. បាននាំចេញក្នុងមួយឆ្នាំ ដោយកំណត់ត្រឹមចំនួន ៥០ មុខ។

៣. **ការពង្រឹងការផ្សារភ្ជាប់រវាង ស.ម.ត.ម. ទៅនឹងខ្សែច្រវាក់តម្លៃក្នុងស្រុក តំបន់ និងសកលលោក** ដែលឆ្លុះបញ្ចាំងតាមរយៈការសម្រេចឱ្យបានត្រឹមឆ្នាំ២០៣០ នូវ៖

១)- ចំនួន ស.ម.ត.ម. ដែលបានផ្គត់ផ្គង់វត្ថុធាតុដើម ឬធាតុចូលផលិតកម្ម ដល់ក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេសបម្រើដល់ការនាំចេញ (Export-oriented FDI) ដោយកំណត់ចំនួន ៥០ សហគ្រាស និង

២)- កម្រិតនៃការផ្សារភ្ជាប់ពីសហគ្រាសមានប្រភពទុនវិនិយោគផ្ទាល់ពីបរទេសទៅកាន់សហគ្រាសក្នុងស្រុក ដោយកំណត់ត្រឹម ២៥% សម្រាប់វិស័យកម្មន្តសាល។

## ៣.៣. ទំហំវិសាលភាព និងអភិក្រមនៃយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រជាតិនេះ មានវិសាលភាពលើ ស.ម.ត.ម. ដែលប្រកបរបររលើគ្រប់វិស័យ រួមទាំងកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម និងពាណិជ្ជកម្ម និងបានចុះបញ្ជីអាជីវកម្មផ្លូវការ តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ស្របតាមនិយមន័យដូចត្រូវបានកំណត់ជាគោល ផ្អែកលើគោលការណ៍នៅក្នុងប្រអប់ខាងក្រោម។

### គោលការណ៍នៃការកំណត់និយមន័យគោល ស.ម.ត.ម.

យោងតាមឧត្តមានុវត្តន៍អន្តរជាតិ និងបទពិសោធកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចយកគោលការណ៍ក្នុងការកំណត់និយមន័យ ស.ម.ត.ម. ដោយបែងចែកតាមវិស័យ និងផ្អែកលើលក្ខខណ្ឌតម្រូវចំនួន ២ រួមមាន៖ ១)-ចំនួនបុគ្គលិកបម្រើការពេញម៉ោង និង ២)-ទំហំផលរបរប្រចាំឆ្នាំ។ ផ្អែកលើលក្ខខណ្ឌតម្រូវទាំង ២ នេះ ការកំណត់សហគ្រាសជា ស.ម.ត.ម. ត្រូវបានបែងចែកជា ២ ករណី ដូចក្នុងតារាងខាងក្រោម៖

**ករណីទី ១៖ លក្ខខណ្ឌតម្រូវទាំង ២ មានសង្គតិភាព**

| លក្ខខណ្ឌ | | ការចាត់ថ្នាក់សហគ្រាស |
|---|---|---|
| ចំនួនបុគ្គលិកបម្រើការពេញម៉ោង | ទំហំផលរបរប្រចាំឆ្នាំ | |
| មីក្រូ | មីក្រូ | សហគ្រាសធុនមីក្រូ |
| តូច | តូច | សហគ្រាសធុនតូច |
| មធ្យម | មធ្យម | សហគ្រាធុនមធ្យម |

**ករណីទី ២៖ ប្រសិនបើលក្ខខណ្ឌតម្រូវទាំង ២ មិនមានសង្គតិភាព ការចាត់ថ្នាក់នឹងត្រូវបានកំណត់ស្របតាមទំហំផលរបរប្រចាំឆ្នាំ**

| លក្ខខណ្ឌ | | ការចាត់ថ្នាក់សហគ្រាស |
|---|---|---|
| ចំនួនបុគ្គលិកបម្រើការពេញម៉ោង | ទំហំផលរបរប្រចាំឆ្នាំ | |
| មីក្រូ | តូច | សហគ្រាសធុនតូច |
| មីក្រូ | មធ្យម | សហគ្រាសធុនមធ្យម |
| តូច | មីក្រូ | សហគ្រាសធុនមីក្រូ |
| តូច | មធ្យម | សហគ្រាធុនមធ្យម |
| មធ្យម | មីក្រូ | សហគ្រាសធុនមីក្រូ |
| មធ្យម | តូច | សហគ្រាសធុនតូច |

បន្ថែមពីនេះ និយមន័យលម្អិតនៃ ស.ម.ត.ម. នឹងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ដែលជាវិធានការគន្លឹះមួយនៃការកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ និងគតិយុត្តពាក់ព័ន្ធក្រោមយុទ្ធសាស្ត្រជាតិនេះ។

ដោយឡែក សកម្មភាពសេដ្ឋកិច្ច និងអាជីវកម្មក្រៅប្រព័ន្ធដែលមិនទាន់បានចុះបញ្ជីស្របច្បាប់ នឹងត្រូវបានគាំទ្រក្រោមយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣–២០២៨។ ជាមួយគ្នានេះ ធុរកិច្ចថ្មី (Startup) នឹងទទួលបានការគាំទ្រជាក់លាក់ ស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍធុរកិច្ចថ្មី ឆ្នាំ២០២៦-២០៣០ ដែលត្រូវបានរាជរដ្ឋាភិបាលប្រកាសដាក់ឱ្យអនុវត្តនាពេលថ្មីៗនេះ។

យុទ្ធសាស្ត្រនេះ ក៏ដើរតួនាទីជាក្របខ័ណ្ឌតភ្ជាប់សម្រាប់ការវិវត្តរបស់អង្គភាពសេដ្ឋកិច្ច ពីសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅជាអាជីវកម្មផ្លូវការ និងពីធុរកិច្ចថ្មីទៅជា ស.ម.ត.ម. ដែលមានសមត្ថភាពប្រកួតប្រជែងនិងការលូតលាស់ប្រកបដោយចីរភាព។ បន្ថែមពីនេះ ការអនុវត្តយុទ្ធសាស្ត្រនេះនឹងផ្តោតជាពិសេសលើ ស.ម.ត.ម. និងវិស័យអាទិភាពដែលមានសក្តានុពលខ្ពស់ក្នុងការបង្កើនផលិតភាព តម្លៃបន្ថែម ការបង្កើតការងារ និងការចូលរួមក្នុងខ្សែច្រវាក់តម្លៃ ក្នុងន័យសម្រេចគោលដៅ និងធានាប្រសិទ្ធភាពនៃវិធានការអន្តរាគមន៍។

ក្នុងន័យនេះ ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍ ស.ម.ត.ម. ឆ្នាំ២០២៦–២០៣០ ត្រូវអនុលោមតាមអភិក្រមសំខាន់ៗដូចខាងក្រោម៖

- ទី១. កំណត់វិសាលភាព និងអាទិភាពភាវូបនីយកម្ម ស.ម.ត.ម. និង
- ទី២. ការបែងចែកសកម្មភាព ការទទួលខុសត្រូវ ដឹកនាំរួម និងតាមវិស័យ។

### ចក្ខុវិស័យ

ជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម កម្ពុជាឱ្យក្លាយជាមូលដ្ឋានគ្រឹះ និងជាកម្លាំងចលករដ៏រឹងមាំ នៃកំណើនសេដ្ឋកិច្ចជាតិ ដែលនឹងនាំមកនូវវឌ្ឍនភាពសង្គម និងវិបុលភាពសម្រាប់ប្រជាជាតិកម្ពុជា

### គោលបំណង

លើកកម្ពស់សមត្ថភាព និងភាពធន់របស់ ស.ម.ត.ម. ឱ្យក្លាយជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសេដ្ឋកិច្ចជាតិតាមរយៈការកសាងមូលដ្ឋានរឹងមាំសម្រាប់ ស.ម.ត.ម. ក្នុងការអភិវឌ្ឍខ្លួនប្រកបដោយភាពធន់ និងចីរភាព ការពង្រឹងសមត្ថភាពផលិតកម្មបំពេញតម្រូវការក្នុងស្រុក និងលទ្ធភាពនាំចេញ និងការពង្រឹងការផ្សារភ្ជាប់រវាង ស.ម.ត.ម. ទៅនឹងខ្សែច្រវាក់តម្លៃក្នុងស្រុក តំបន់ និងសកលលោក

### គោលដៅ

| | | |
|---|---|---|
| កសាងមូលដ្ឋានរឹងមាំសម្រាប់ ស.ម.ត.ម. ក្នុងការអភិវឌ្ឍខ្លួនប្រកបដោយភាពធន់ និងចីរភាព | ពង្រឹងសមត្ថភាពផលិតកម្មបំពេញតម្រូវការក្នុងស្រុកនិងលទ្ធភាពនាំចេញរបស់ ស.ម.ត.ម. | ពង្រឹងការផ្សារភ្ជាប់រវាង ស.ម.ត.ម. ទៅនឹងខ្សែច្រវាក់តម្លៃក្នុងស្រុក តំបន់ និងសកលលោក |

# ផ្នែកទី៤
# យុទ្ធសាស្ត្រអភិវឌ្ឍន៍សហគ្រាសធុនមីក្រូ តូច និងមធ្យមកម្ពុជា

## ៤.១. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗចំនួន ៤ ដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១៖ ការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់

យុទ្ធសាស្ត្រទី២៖ ការលើកកម្ពស់សមត្ថភាព ផលិតកម្ម សេវាកម្ម និងការចាប់យកបច្ចេកវិទ្យា និងនវានុវត្តន៍

យុទ្ធសាស្ត្រទី៣៖ ការបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារជាតិ និងអន្តរជាតិ

យុទ្ធសាស្ត្រទី៤៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។



## ៤.១.១. ការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់

យុទ្ធសាស្ត្រនេះនឹងផ្តោតលើការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់ តាមរយៈការកាត់បន្ថយឧបសគ្គផ្នែកច្បាប់និងរដ្ឋបាល ការបង្កើនប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគាំទ្រ ស.ម.ត.ម. ការបង្កើនទំនុកចិត្តរបស់វិនិយោគិន សំដៅសម្រួលលទ្ធភាពដល់ ស.ម.ត.ម. ក្នុងការកសាងមូលដ្ឋាន ពង្រីកខ្លួន និងពង្រឹងសមត្ថភាពប្រកបដោយភាពធន់ និងចីរភាព។ ក្នុងការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់ យុទ្ធសាស្ត្រនេះផ្តោតលើ ៣ ទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម៖

### ៤.១.១.១. ការកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ និងគតិយុត្តពាក់ព័ន្ធ

ការកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ និងគតិយុត្ត នឹងផ្តោតសំខាន់លើគ្រប់ដំណាក់កាល គិតចាប់ពីការស្នើសុំបើកអាជីវកម្ម កិច្ចដំណើរការ និងការស្នើសុំបិទ ឱ្យបានច្បាស់លាស់ និងមានតម្លាភាព ដែលជាគ្រឹះសំខាន់សម្រាប់ការរីកចម្រើនរបស់ ស.ម.ត.ម. និងបង្កើនទំនុកចិត្តរបស់វិនិយោគិន។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការគន្លឹះ ដូចខាងក្រោម៖

១. កំណត់លម្អិតនូវនិយមន័យ ស.ម.ត.ម. ឱ្យមានភាពច្បាស់លាស់ និងមានភាពជាក់ស្តែង និយមដែលអាចអនុវត្តសម្រាប់រាល់ក្រសួង ស្ថាប័ន ប្រកបដោយសង្គតិភាព។

២. រៀបចំយន្តការផ្តល់ការលើកទឹកចិត្តដល់ ស.ម.ត.ម. ជារួម ឬតាមវិស័យ ដោយផ្តោតលើការលើកទឹកចិត្តផ្នែកពន្ធដារ និងផ្នែកគយ ការកាត់បន្ថយ ឬសាមញ្ញកម្មបន្ទុកសារពើពន្ធផ្សេងទៀត ការសម្របសម្រួលលក្ខខណ្ឌធុរកិច្ច ការសម្រួលនីតិវិធីស្នើសុំឯកសារ និងការនាំចេញ នាំចូល និងការអនុគ្រោះពេល (Grace Period) សម្រាប់បំពេញអនុលោមភាពចុះបញ្ជី សំដៅជំរុញការចុះបញ្ជីផ្លូវការរបស់ ស.ម.ត.ម. និងផ្តល់ការគាំទ្រដល់ ស.ម.ត.ម. ដែលមានលទ្ធភាព និងសក្តានុពលពិតប្រាកដក្នុងការអភិវឌ្ឍសហគ្រាស។

៣. រៀបចំយន្តការជម្រះបញ្ជីដើម្បីបិទសហគ្រាសប្រកបដោយភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយដោយធានាបាននូវភាពសាមញ្ញនិងប្រសិទ្ធភាពនិងការពារការគេចវេសកាតព្វកិច្ចណាមួយ។

៤. ពង្រឹងការអនុវត្ត និងធ្វើបច្ចុប្បន្នភាពនូវបទប្បញ្ញត្តិ និងគតិយុត្តពាក់ព័ន្ធ ដើម្បីសម្រួលដល់ប្រតិបត្តិការរបស់ ស.ម.ត.ម.។

៥. សិក្សា និងកាត់បន្ថយក្របខ័ណ្ឌគតិយុត្តដែលមានជាធរមានដូចជា (អាជ្ញាបណ្ណ លិខិតអនុញ្ញាត ធ្វើសាមញ្ញកម្មលើការងារអធិការកិច្ច ការងារត្រួតពិនិត្យអនុលោមភាពជាដើម) មកលើ ស.ម.ត.ម. ចៀសវាងការអនុវត្តត្រួតគ្នានាំឱ្យមានចំណាយថវិកា ពេលវេលាច្រើន ថ្លៃដើមខ្ពស់ និងធានាបានប្រកួតប្រជែងស្មើភាព។

៦. បង្កើនការផ្សព្វផ្សាយស្តីពីបទដ្ឋានគតិយុត្តនានារបស់ ស.ម.ត.ម. ដល់ធុរជន។

៧. រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអភិវឌ្ឍ ស.ម.ត.ម. ដែលរួមបញ្ចូលនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់និយមន័យ និងលក្ខខណ្ឌចាត់ថ្នាក់ ទម្រង់នីតិបុគ្គល យន្តការចាត់

ថ្នាក់ របបអាជ្ញាបណ្ណ កញ្ចប់អន្តរាគមន៍ យន្តការចាត់ថ្នាក់ឡើងវិញ និងការចាកចេញពីស្ថានភាពជា ស.ម.ត.ម. និងការបិទសហគ្រាស។

### ៤.១.១.២. ការបន្តកែលម្អប្រព័ន្ធផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច

ផ្នែកនេះនឹងពិនិត្យឡើងវិញ និងកែសម្រួលនូវប្រព័ន្ធផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច រាប់ពីយន្តការចុះបញ្ជីពាណិជ្ជកម្ម និងការស្នើសុំអាជ្ញាបណ្ណពាក់ព័ន្ធ ក៏ដូចជាការទទួលស្គាល់ជា ស.ម.ត.ម. ជាដើម សំដៅពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃប្រព័ន្ធ និងផ្តល់ភាពងាយស្រួលសម្រាប់ធុរជន។ ស្របតាមគោលដៅនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធចុះបញ្ជីអាជីវកម្ម និងការចាត់ថ្នាក់ សម្រាប់ ស.ម.ត.ម. លើថ្នាលឌីជីថលរួម (Single Portal) ដែលមានលក្ខណៈសាមញ្ញ និងមិនទាមទារព័ត៌មានច្រើន ដោយដាក់បន្ថែមនូវយន្តការចាត់ថ្នាក់ និងទទួលស្គាល់ ស.ម.ត.ម. ជាផ្លូវការក្នុងពេលចុះបញ្ជីតែម្តង។

២. ឌីជីថលូបនីយកម្មប្រព័ន្ធសេវាសាធារណៈ ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព អន្តរប្រតិបត្តិការ សន្តិសុខទិន្នន័យ និងការផ្តល់សេវាកាន់តែជិតដល់ប្រជាពលរដ្ឋ និងធុរកិច្ច។

៣. សិក្សា និងកំណត់យន្តការចាត់ថ្នាក់ឡើងវិញ (Reclassifications) ដែលត្រូវអនុវត្តរៀងរាល់ ៣ ឆ្នាំម្តង សំដៅផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពនូវទំហំ និងស្ថានភាព ស.ម.ត.ម. ទាំងថ្មី ទាំងចាស់ ដែលបានចុះបញ្ជី។

៤. រៀបចំយន្តការផ្តល់ទិន្នន័យ និងចែករំលែកព័ត៌មាន ទំនាក់ទំនងសាធារណៈ ប្រព័ន្ធទទួលបណ្តឹងតវ៉ា និងសេវាប្រឹក្សាយោបល់។

៥. រៀបចំតុសេវាគាំទ្រ (Support Desk) ឬសេវាប្រឹក្សាអនឡាញ សម្រាប់ជួយគាំទ្រ និងសម្រួលនីតិវិធីនាំចេញ នាំចូលដល់ ស.ម.ត.ម.។

### ៤.១.១.៣. ការពង្រឹងសមត្ថភាពវិស័យសាធារណៈ និងការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន

ផ្នែកនេះនឹងបង្កើនសមត្ថភាពស្ថាប័នសាធារណៈក្នុងការដឹកនាំគ្រប់គ្រង និងតាមដានស្ថានភាពរបស់ ស.ម.ត.ម. ដោយផ្តោតលើការកែលម្អប្រសិទ្ធភាព និងពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ ក៏ដូចជាផ្តោតលើកិច្ចសហការជាមួយវិស័យឯកជនសម្រាប់ការអភិវឌ្ឍ ស.ម.ត.ម. ប្រកបដោយបរិយាបន្ន និងចីរភាព។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. ពង្រឹងសមាគម/សហព័ន្ធសមាគមតំណាង ស.ម.ត.ម. ទូទាំងប្រទេស ដើម្បីធ្វើជាដៃគូជាមួយវិស័យសាធារណៈ ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធផ្សេងទៀត និងលើកកម្ពស់កិច្ច

ពិគ្រោះយោបល់រវាងតំណាង ស.ម.ត.ម. ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន (G-PSF)។

២. ពង្រឹងសមត្ថភាពមន្ត្រីសាធារណៈ ឱ្យស្របតាមក្របខ័ណ្ឌគោលនយោបាយ និងពង្រឹងអភិបាលកិច្ចសម្រាប់គាំទ្រ ស.ម.ត.ម.។

៣. រៀបចំយន្តការពង្រឹងសមត្ថភាពដល់ ស.ម.ត. ម. ក្នុងការគ្រប់គ្រងអាជីវកម្ម ប្រកបដោយចីរភាពលើការគ្រប់គ្រងអង្គភាព ចំណេះដឹងហិរញ្ញវត្ថុនិងឌីជីថល និងការយល់ដឹងអំពីបទដ្ឋានគតិយុត្ត និងគោលនយោបាយ។

៤. បន្តលើកកម្ពស់សហគ្រិនភាពស្ត្រី និងគាំទ្រដល់ ស.ម.ត.ម. ដឹកនាំដោយស្ត្រីតាមរយៈការពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហគ្រិនភាពស្ត្រី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅតាមបណ្តាខេត្ត។

## ៤.១.២. ការលើកកម្ពស់សមត្ថភាពផលិតកម្ម សេវាកម្ម និងការចាប់យកបច្ចេកវិទ្យា និងនវានុវត្តន៍

យុទ្ធសាស្ត្រនេះនឹងផ្តោតចម្បងលើការលើកកម្ពស់សមត្ថភាពផលិតកម្ម និងការផ្តល់សេវាកម្មរបស់ ស.ម.ត.ម. ប្រកបដោយគុណភាព ដើម្បីបំពេញតម្រូវការក្នុងស្រុកជំនួសការនាំចូល និងអាចមានលទ្ធភាពជំរុញការនាំចេញ តាមរយៈការចាប់យកបច្ចេកវិទ្យា ការអភិវឌ្ឍសមត្ថភាព និងការផ្សារភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃក្នុងស្រុក ក្នុងតំបន់ និងសកល។ ក្នុងការលើកកម្ពស់សមត្ថភាពផលិតកម្ម សេវាកម្ម និងការចាប់យកបច្ចេកវិទ្យា និងនវានុវត្តន៍ រាជរដ្ឋាភិបាលផ្តោតលើទិដ្ឋភាពសំខាន់ៗចំនួន ៣ ដូចខាងក្រោម៖

### ៤.១.២.១. ការលើកកម្ពស់សហគ្រិនភាព និងការបង្កើនការអភិវឌ្ឍបច្ចេកវិទ្យា និងនវានុវត្តន៍

ការលើកកម្ពស់សហគ្រិនភាពនិងការបង្កើនការអភិវឌ្ឍបច្ចេកវិទ្យា និងនវានុវត្តន៍នឹងពង្រឹងសមត្ថភាពជំនាញ និងបច្ចេកទេស ក៏ដូចជាការចាប់យកបច្ចេកវិទ្យារបស់ ស.ម.ត.ម. ដែលជាផ្នែកសំខាន់ក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. បង្កើតកម្មវិធីជំនួយបច្ចេកទេស និងបណ្តុះបណ្តាលបុគ្គលិក ស.ម.ត.ម. ផ្តោតលើការផ្ទេរបច្ចេកវិទ្យា និងនវានុវត្តន៍ ការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការគ្រប់គ្រងធុរកិច្ច និងការបង្កើនផលិតភាពនិងគុណភាព ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងដល់ ស.ម.ត.ម. នៅក្នុងទីផ្សារជាតិ និងអន្តរជាតិ។

២. លើកទឹកចិត្តឱ្យ ស.ម.ត.ម. ប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទីផ្សារឌីជីថល បច្ចេកវិទ្យាហិរញ្ញវត្ថុ កម្មវិធីគណនេយ្យ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា និងឧបករណ៍បញ្ញាសិប្បនិម្មិត ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងធុរកិច្ច។

៣. រៀបចំយន្តការជំរុញ និងលើកទឹកចិត្ត ស.ម.ត.ម. ក្នុងការធ្វើឌីជីថលូបនីយកម្មនៃដំណើរការផលិត កែច្នៃ និងសេវាកម្ម តាមរយៈការចាប់យកបច្ចេកវិទ្យា និងប្រើប្រាស់

សម្ភារឧបករណ៍ទំនើបៗ ដែលជួយបង្កើនផលិតភាព។

៤. ពង្រឹងការការពារកម្មសិទ្ធិបញ្ញា ដើម្បីជំរុញការសិក្សាស្រាវជ្រាវបង្កើតតក្កកម្មថ្មី និងការប្រកួតប្រជែងប្រកបដោយចីរភាព និងប្រមូលផ្តុំចងក្រងប្រព័ន្ធទិន្នន័យនិងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងអំពីកម្មសិទ្ធិបញ្ញានានា។

៥. ជំរុញការផ្សារភ្ជាប់រវាងប្រតិបត្តិករសិល្បៈប្រពៃណីជាមួយវិនិយោគិននិងអ្នកច្នៃប្រតិដ្ឋ ដើម្បីលើកកម្ពស់តម្លៃវប្បធម៌លើផលិតផលកម្ពុជា។

៦. លើកទឹកចិត្តការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) និងគម្រោងច្នៃប្រតិដ្ឋតាមរយៈការគាំទ្រធនធានដោយមូលនិធិស្រាវជ្រាវជាតិ។

### ៤.១.២.២. ការជំរុញការតភ្ជាប់ខ្សែច្រវាក់តម្លៃសកលរបស់ ស.ម.ត.ម. ជាមួយឧស្សាហកម្មប្រតិគមន៍ (Backward Linkage) និងអនុគមន៍ (Forward Linkage)

វិធានការនេះ នឹងបង្កើតនូវប្រព័ន្ធអេកូឡូស៊ីថ្មីមួយ ដែលលើកកម្ពស់សមត្ថភាពតភ្ជាប់របស់ ស.ម.ត.ម. ទៅក្នុងខ្សែច្រវាក់តម្លៃសកល តាមរយៈឧស្សាហកម្មប្រតិគមន៍ និងឧស្សាហកម្មអនុគមន៍ដែលជាសមាសធាតុសំខាន់មួយនៃការអភិវឌ្ឍ ស.ម.ត.ម.។ បច្ចុប្បន្ន ស.ម.ត.ម. ភាគច្រើននៅតែបន្តប្រតិបត្តិការផ្តាល់ខ្លួន មិនទាន់ភ្ជាប់ទៅឧស្សាហកម្មធំៗ ឬទីផ្សារអន្តរជាតិនៅឡើយ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. សិក្សា និងដាក់ឱ្យអនុវត្តកម្មវិធីជំរុញការតភ្ជាប់រវាង ស.ម.ត.ម. ជាមួយក្រុមហ៊ុនវិនិយោគពីបរទេសបម្រើការនាំចេញ សហគ្រាសធុនធំ និងអ្នកកែច្នៃក្នុងស្រុក តាមរយៈការរៀបចំព្រឹត្តិការណ៍ និងកម្មវិធីផ្គូផ្គងអាជីវកម្មរវាងសហគ្រាសធុនធំ និង ស.ម.ត.ម. កម្មវិធីអភិវឌ្ឍអ្នកផ្គត់ផ្គង់ ការសម្របសម្រួលព័ត៌មាន ការលើកកម្ពស់សមត្ថភាព ការគាំទ្រហិរញ្ញប្បទាន និងការគាំទ្របច្ចេកទេស សំដៅផ្សារភ្ជាប់ខ្សែច្រវាក់តម្លៃក្នុងស្រុក និងលើកកម្ពស់សមត្ថភាពឧស្សាហកម្មរបស់ ស.ម.ត.ម.។

២. ពង្រឹងគុណភាពផលិតផល ឬសេវារបស់ ស.ម.ត.ម. ឱ្យស្របតាមស្តង់ដា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសធំៗ អ្នកកែច្នៃ និងអ្នកទិញក្នុងខ្សែច្រវាក់តម្លៃ។

៣. រៀបចំ និងអនុវត្តកម្មវិធីទិញពីក្នុងស្រុក (Local Sourcing) និងកិច្ចសន្យាផ្គត់ផ្គង់ (Sub-contracting) ជាមួយឧស្សាហកម្មដែលស្ថិតនៅក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស ដើម្បីបង្កើនការប្រើប្រាស់ធាតុចូល និងសេវាកម្មក្នុងស្រុក។

៤. ពង្រឹងយន្តការ និងផ្តល់ជំនួយហិរញ្ញវត្ថុតាម SME Linkage Fund ឬកម្មវិធីជំនួយផ្គូផ្គង (Matching Grant) តាមរយៈសហគ្រិនខ្មែរ ដើម្បីកែលម្អសមត្ថភាពផលិត និងគុណភាព។

៥. ជំរុញការផ្សារភ្ជាប់រវាងក្រុមផលិតកម្មកសិកម្ម ជាមួយនឹងអ្នកកែច្នៃ អ្នកប្រមូលទិញ អ្នកចែកចាយ និងទីផ្សារ សំដៅគាំទ្រប្រតិបត្តិការផលិតរបស់ ស.ម.ត.ម.។

### ៤.១.២.៣. ការជំរុញអនុវត្តន៍ផលិតកម្ម និងសេវាកម្មបៃតង និងសេដ្ឋកិច្ចចក្រា

ទិដ្ឋភាពនេះនឹងផ្ដោតលើការពង្រឹងផលិតកម្ម សេវាកម្មបៃតង និងការអនុវត្តសេដ្ឋកិច្ចចក្រា ស្របតាមគោលការណ៍សេដ្ឋកិច្ចបៃតង និងសេដ្ឋកិច្ចចីរភាព ក្នុងន័យចូលរួមចំណែកកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ក៏ដូចជាសម្របជាមួយនិន្នាការទីផ្សារថ្មីៗ ជាពិសេសសម្រាប់ការនាំចេញ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖៖

១. លើកទឹកចិត្តឱ្យ ស.ម.ត.ម. អនុវត្តកម្មវិធីផលិតកម្ម និងសេវាកម្មបៃតង ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិ និងថាមពល កាត់បន្ថយការបំពុលបរិស្ថាន និងគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទយ៉ាងមានប្រសិទ្ធភាព។

២. លើកទឹកចិត្តឱ្យ ស.ម.ត.ម. ផលិតតាមគោលការណ៍សេដ្ឋកិច្ចចក្រា (Circular Economy) ដើម្បីចម្រាញ់ និងកែច្នៃសំណល់ឧស្សាហកម្ម ឱ្យក្លាយជាផលិតផលថ្មីដែលអាចបង្កើនតម្លៃបន្ថែម។

៣. លើកទឹកចិត្តឱ្យ ស.ម.ត.ម. ប្រើប្រាស់ស្លាកសញ្ញាបៃតងសម្រាប់ផលិតផលដែលគោរពតាមស្តង់ដាសុវត្ថិភាពបរិស្ថាន និងផលិតតាមគោលការណ៍ចីរភាព ដើម្បីលើកកម្ពស់ភាពទុកចិត្តរបស់ទីផ្សារ និងសមត្ថភាពប្រកួតប្រជែងក្នុងស្រុក និងអន្តរជាតិ។

៤. ផ្តល់ការលើកទឹកចិត្តចំពោះ ស.ម.ត.ម. ដែលអនុវត្តមេត្រីភាពបរិស្ថានបានជោគជ័យនៅក្នុងអាជីវកម្មរបស់ខ្លួន។

## ៤.១.៣. ការបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារជាតិ និងអន្តរជាតិ

ការបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារជាតិ និងអន្តរជាតិ គឺជាយុទ្ធសាស្ត្រសំខាន់មួយក្នុងការឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ចសកល ដែលទីផ្សារមានការប្រកួតប្រជែងខ្ពស់ និងតម្រូវឱ្យមានការបង្កើនផលិតភាព គុណភាព និងស្តង់ដា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ ស.ម.ត.ម. ដោយផ្ដោតលើទិដ្ឋភាពចំនួន ៣ ដូចខាងក្រោម៖

### ៤.១.៣.១. ការជំរុញ និងការលើកកម្ពស់ផលិតភាព

ការលើកកម្ពស់ផលិតភាព នឹងផ្ដោតលើការជំរុញការផលិតប្រកបដោយភាពច្នៃប្រតិដ្ឋ កាត់បន្ថយថ្លៃដើម បង្កើនគុណភាព ធ្វើសមាហរណកម្មបច្ចេកវិទ្យា ពង្រឹងសមត្ថភាពបុគ្គលិក និងបង្កើនប្រសិទ្ធភាពដំណើរការផលិត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. ជំរុញការអនុវត្តកម្មវិធី ជំរុញផលិតកម្មក្នុងស្រុក សម្រាប់ជំនួសការនាំចូល លើមុខទំនិញយុទ្ធសាស្ត្រដែលមានសក្តានុពល និងផ្តល់ការគាំទ្រទាំងលើទិដ្ឋភាពហិរញ្ញវត្ថុ មិនមែនហិរញ្ញវត្ថុ បច្ចេកទេស និងការគាំទ្រអនុលោមភាព។

២. ជំរុញអនុវត្តឧបករណ៍ផលិតភាព ដូចជាវិធីសាស្ត្រ "ស៥" (5S) រង្វង់ត្រួតពិនិត្យគុណភាព (Quality Control Circle) ខាយហ្សិន (Kaizen) ប្រព័ន្ធលីន (LEAN) ផលិតកម្មស្អាត (Cleaner Production) និងផលិតភាពបៃតង (Green Productivity) និងការគ្រប់គ្រងគុណភាពសរុប (Total Quality Management)។

៣. ជំរុញការប្រែក្លាយ ស.ម.ត.ម. បែបគ្រួសារ ទៅជា ស.ម.ត.ម. បែបឧស្សាហកម្ម និងការគាំទ្រជំនួយហិរញ្ញវត្ថុ តាមរយៈមូលនិធិលើកកម្ពស់ផលិតភាព ឬកម្មវិធីជំនួយផ្គូផ្គងដើម្បីផ្ទេរបច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងខ្សែច្រវាក់ផលិតកម្ម។

៤. បង្កើតសន្ទស្សន៍ផលិតភាពមធ្យមសម្រាប់ធ្វើជាមូលដ្ឋានក្នុងការវាស់វែង និងឆ្លុះបញ្ចាំងស្ថានភាពសេដ្ឋកិច្ច ការគ្រប់គ្រង និងកម្រិតផលិតភាពនៃ ស.ម.ត.ម. ដើម្បីធ្វើការប្រៀបធៀបសន្ទស្សន៍នេះជាមួយផលិតភាពអន្តរជាតិ។

### ៤.១.៣.២. ការលើកកម្ពស់គុណភាព និងស្តង់ដា

ការលើកកម្ពស់គុណភាព និងស្តង់ដាផលិតផលរបស់ ស.ម.ត.ម. នឹងត្រូវជំរុញតាមរយៈការពង្រឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ និងការជំរុញឱ្យ ស.ម.ត.ម. លើកកម្ពស់គុណភាពផលិតឱ្យស្របតាមស្តង់ដាអន្តរជាតិ ដូចជា៖ ISO, HACCP, GMP, Halal និង Organic Certification ជាដើម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. សិក្សា រៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីជំរុញការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ដោយផ្តោតលើមុខទំនិញដែលមានសក្តានុពលក្នុងការនាំចេញ និងមានឧត្តមភាពប្រកួតប្រជែង តាមរយៈការគាំទ្រលើទិដ្ឋភាពហិរញ្ញប្បទាន បច្ចេកទេស ទីផ្សារ និងបទដ្ឋានគតិយុត្ត។

២. ពង្រឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ដោយកសាង និងវិនិយោគបន្ថែមលើការបង្កើត និងលើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលមាត្រាសាស្ត្រ ការលើកកម្ពស់លទ្ធផលតេស្តនិងវិភាគអធិការកិច្ចនិងវិញ្ញាបនបត្រផលិតផលរបស់កម្ពុជាឱ្យស្របតាមស្តង់ដាអន្តរជាតិ តាមរយៈការបង្កើនការគាំទ្រផ្នែកបច្ចេកទេស ការបណ្តុះបណ្តាលធនធានមនុស្សនៃមន្ទីរពិសោធន៍តេស្ត និងអ្នកប្រឹក្សាឯកទេសដល់ ស.ម.ត.ម. ដើម្បីទទួលបានវិញ្ញាបនបត្រអន្តរជាតិ ដូចជា ISO, HACCP, GMP និង Eco-label ជាដើម។

៣. ពង្រឹងសមត្ថភាព ស.ម.ត.ម. លើការគ្រប់គ្រងគុណភាព ការរចនាផលិតផល និងនវានុវត្តន៍សំបកវេចខ្ចប់។

៤. កសាងម៉ាក «Made in Cambodia» ដោយផ្តោតលើការបង្កើនគុណភាព សោភ័ណភាពផលិតផល កសាងទំនុកចិត្ត និងទាក់ទាញអ្នកប្រើប្រាស់ក្នុងស្រុក និងអន្តរជាតិ ព្រមទាំងលើកទឹកចិត្តឱ្យ ស.ម.ត.ម. ប្រើប្រាស់ស្លាកសញ្ញាបញ្ជាក់ប្រភពផលិតកម្ម

ដូចជា "Sourced in Cambodia" "Packaged in Cambodia" "Made in Cambodia" និង "Product of Cambodia" សម្រាប់ផលិតផលដែលបានផលិត ផ្គុំ ដំឡើង កែច្នៃ បំលែង ឬដំណើរការនៅកម្ពុជា និងគោរពតាមស្តង់ដាគុណភាព និងសុវត្ថិភាព។

៥. ផ្សព្វផ្សាយ និងសហការផ្នែកទីផ្សារ ពង្រីកទីផ្សារ និងអភិវឌ្ឍស្តង់ដាថ្មីៗ សម្រាប់ការនាំចេញ តាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាក្នុងការធ្វើទំនើបកម្មខ្សែច្រវាក់ផលិតកម្ម។

៦. ជំរុញការអនុវត្តស្តង់ដា ការអនុវត្តកសិកម្មល្អ (GAP) ការអនុវត្តអនាម័យសត្វល្អ (GAHP) និងការអនុវត្តវារីវប្បកម្មល្អ (GAQP) ដើម្បីធានាគុណភាព សុវត្ថិភាព និងភាពប្រកួតប្រជែងនៃផលិតផលកសិកម្ម កសិឧស្សាហកម្ម និងវារីវប្បកម្ម។

៧. សម្របសម្រួល និងគាំទ្រការតភ្ជាប់ទីផ្សារក្នុងស្រុក នូវផលិតផល ស.ម.ត.ម. នៅក្នុងផ្សារទំនើប។

៨. ជំរុញ និងផ្តល់ការគាំទ្រដល់ ស.ម.ត.ម. ចូលរួមពិព័រណ៍អន្តរជាតិ ដើម្បីយល់ដឹងពីបច្ចេកវិទ្យាថ្មីៗ តម្រូវការទីផ្សារអន្តរជាតិ ជាពិសេសសម្រាប់សហគ្រិនស្ត្រី និងវិស័យដែលមានសក្តានុពលក្នុងការនាំចេញ។

៩. កំណត់វិធានការគ្រប់គ្រងទំនិញនាំចូល ទាំងលើទំនិញជាម្ហូបអាហារ មិនមែនម្ហូបអាហារ ឧបករណ៍ និងសម្ភារប្រើប្រាស់ ដោយកំណត់នូវលក្ខខណ្ឌចុះបញ្ជី ច.ប.ផ. ការរាយការណ៍ព័ត៌មានផលិតផល និងវិធីប្រើប្រាស់ និងត្រូវភ្ជាប់នូវឯកសារបញ្ជាក់គុណភាព និងសុវត្ថិភាពផលិតផល។

### ៤.១.៣.៣. ការពង្រឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្ម ទ្វេភាគីនិងពហុភាគី ទាំងកម្រិតជាតិ និងអន្តរជាតិ

ក្នុងទិដ្ឋភាពនេះ ស.ម.ត.ម. ទទួលបានឱកាសក្នុងការជ្រៀតចូលទៅក្នុងទីផ្សារជាតិ និងអន្តរជាតិ តាមរយៈការចាប់យកនូវកាលានុវត្តន៍ថ្មីនៃការធ្វើពិពិធកម្មផលិតផល និងសេវាកម្មឱ្យស្របតាមស្តង់ដាអន្តរជាតិ សំដៅលើកកម្ពស់សមត្ថភាព និងគុណភាពក្នុងការនាំចេញរបស់ ស.ម.ត.ម. ទៅកាន់ទីផ្សារជាដៃគូ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. បង្កើនការផ្តល់ព័ត៌មាន និងលើកកម្ពស់ការយល់ដឹងដល់ ស.ម.ត.ម. អំពីនីតិវិធី និងបែបបទនៃការនាំចេញ ឱ្យស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ និងអន្តរជាតិ ដល់ ស.ម.ត.ម. តាមរយៈការរៀបចំប្រមូលផ្តុំ និងចងក្រងឯកសារព័ត៌មាន និងផ្សព្វផ្សាយគ្រប់ប្រភេទ ស្តីពីតម្រូវការស្តង់ដាគុណភាពផលិតផល និងលក្ខខណ្ឌនាំចេញរបស់ប្រទេសហត្ថលេខី អនុស្សរណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីបង្កើនការយល់ដឹង និងការចាប់យកឱកាសទីផ្សារថ្មីៗ។

២. សិក្សា និងរៀបចំយន្តការផ្តល់ការបញ្ជាក់ប្រភពដើមនៃទំនិញ (Traceability) លើផលិតផលសម្រាប់នាំចេញ ដោយផ្តោតលើផលិតផលដែលមានសក្តានុពលមួយចំនួនដែលអាចអនុលោមតាមស្តង់ដាបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។
៣. ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទីផ្សារ ឱកាសអាជីវកម្ម និងតម្រូវការខ្សែច្រវាក់តម្លៃក្នុងតំបន់ និងសកល ដល់ ស.ម.ត.ម. សម្រាប់ផលិតផល កសិផលកែច្នៃ និងសេវាកម្ម។

## ៤.១.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ

ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលមានប្រសិទ្ធភាព គឺជាចំណុចសំខាន់ ដើម្បីជួយសម្រួលដល់ប្រតិបត្តិការរបស់ ស.ម.ត.ម. ក្នុងការពង្រីកវិសាលភាពផលិតកម្ម និងធានាឱ្យវិស័យនេះអាចលូតលាស់បានយ៉ាងរឹងមាំ។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលដាក់ចេញនូវយន្តការគាំទ្រសំខាន់ៗ ដូចខាងក្រោម៖

### ៤.១.៤.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ ស.ម.ត.ម.

ទិដ្ឋភាពនេះនឹងផ្តោតលើការពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានស្រាប់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដើម្បីធានាដល់ការបង្កើនផលិតភាព ភាពប្រកួតប្រជែង និងពិពិធកម្មមុខទំនិញរបស់ ស.ម.ត.ម.។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញវិធានការសំខាន់ៗ រួមមាន៖

១. រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម។
២. ជំរុញការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម នៅតាមតំបន់សំខាន់ៗ ផ្តោតលើការផ្តល់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា ផ្លូវ បណ្តាញអគ្គិសនី ទឹកស្អាត ទូរគមនាគមន៍ និងប្រព័ន្ធគ្រប់គ្រងកាកសំណល់ប្រកបដោយសុវត្ថិភាព តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន (PPP) និងទាក់ទាញវិនិយោគឯកជន។
៣. ពង្រឹងការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពលកកើតឡើងវិញ និងថាមពលស្អាត ក៏ដូចជាជំរុញប្រសិទ្ធភាពថាមពល។
៤. បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្គត់ផ្គង់ ស.ម.ត.ម. ដើម្បីបង្ហាញពីសមត្ថភាពផលិតកម្ម និងសេវាកម្ម។

### ៤.១.៤.២. ការបង្កើនលទ្ធភាពទទួលហិរញ្ញប្បទាន និងឥណទាន

ក្នុងទិដ្ឋភាពសម្រួលលទ្ធភាពទទួលបានហិរញ្ញប្បទាន រាជរដ្ឋាភិបាលនឹងបង្កើតលក្ខខណ្ឌអំណោយផលដល់ ស.ម.ត.ម. ក្នុងការចូលប្រើប្រាស់ប្រភពហិរញ្ញវត្ថុនានា ដើម្បីពង្រីកវិសាលភាពនៃផលិតកម្មរបស់ខ្លួន។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. ជំរុញផលិតផលហិរញ្ញប្បទានដែលមានលក្ខខណ្ឌស្របតាមតម្រូវការរបស់ ស.ម.ត.ម. មានជាអាទិ៍ ហិរញ្ញប្បទានចម្រុះ (Blended Financing) ហិរញ្ញប្បទានតាមខ្សែច្រវាក់

ផ្គត់ផ្គង់ (Supply Chain Financing) ហិរញ្ញប្បទានពាណិជ្ជកម្ម (Trade Finance) និងហិរញ្ញប្បទានតាមរយៈការដាក់ផែនការអាជីវកម្ម ចំណូល និងចំណាយជាដើម ដើម្បីជួយ ស.ម.ត.ម. ក្នុងការបង្កើនទុនបង្វិល និងទុនវិនិយោគ។

២. ជំរុញសេវាគាំទ្រលើសពីហិរញ្ញប្បទាន (Beyond Financing) ដើម្បីបង្កើតម្លៃបន្ថែមជូនអតិថិជន និងគាំទ្រ ស.ម.ត.ម. ក្នុងការចុះបញ្ជីអាជីវកម្ម ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ និងការផ្តល់ប្រឹក្សាផ្នែកច្បាប់ ពាក់ព័ន្ធនឹងការគោរពបទប្បញ្ញត្តិជាធរមាន។

៣. បន្តពង្រឹងប្រព័ន្ធធានាឥណទានរបស់រាជរដ្ឋាភិបាលតាមរយៈសាជីវកម្មធានាឥណទានកម្ពុជាដើម្បី សម្រួលបន្ថែមដល់លទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ ស.ម.ត.ម. ក្នុងការពង្រីកសមត្ថភាពប្រតិបត្តិការ។

៤. ជំរុញការចូលរួមពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍អន្តរជាតិ ដែលអាចផ្តល់ជំនួតឥណទានប្រាក់បញ្ញើ ឬវិនិយោគ តាមវិធីសាស្ត្រសមរម្យ ក្នុងការផ្តល់ជំនួយឥណទាន បង្កើតមូលនិធិសហហិរញ្ញប្បទានសម្រាប់ ស.ម.ត.ម.។

៥. រៀបចំកម្មវិធីការចាប់យកឌីជីថលរបស់សហគ្រាស ដូចជាការបណ្តុះបណ្តាលអំពី Digital Accounting, E-invoicing ទម្រង់របាយការណ៍ហិរញ្ញវត្ថុសាមញ្ញ ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល និងឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យ ស.ម.ត.ម. អាចគ្រប់គ្រងសាច់ប្រាក់ និងធនធានហិរញ្ញវត្ថុបានប្រកបដោយប្រសិទ្ធភាព។

៦. ជំរុញការផ្តល់ឱកាសឱ្យ ស.ម.ត.ម. ដែលមានសមត្ថភាពប្រតិបត្តិការល្អ និងមានការកាន់បញ្ជីគណនេយ្យត្រឹមត្រូវ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ចូលរួមក្នុង SME Board នៃទីផ្សារមូលបត្រកម្ពុជា ដើម្បីរកប្រាក់វិនិយោគបន្ថែម និងបង្កើតភាពជឿជាក់របស់វិនិយោគិន។

៧. ជំរុញឱ្យ ស.ម.ត.ម. ប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុឯកជន ដូចជា Venture Capital Funds ការទទួលបានហិរញ្ញប្បទានតាមទីផ្សារមូលបត្រ ដើម្បីទាក់ទាញវិនិយោគពីវិស័យឯកជន និងទទួលបានធនធានវិនិយោគរយៈពេលវែង សម្រាប់ពង្រីកសមត្ថភាពផលិត ការច្នៃប្រតិដ្ឋ និងចូលទៅក្នុងទីផ្សារអន្តរជាតិ។

៨. ពង្រឹងប្រព័ន្ធធានាឥណទាន ការអភិវឌ្ឍ Fintech និងថ្នាលឥណទានឌីជីថល ដើម្បីសម្រួលដល់ស.ម.ត.ម. ក្នុងដំណើរការហិរញ្ញវត្ថុ និងឥណទាន។

៩. ផ្តល់អាទិភាពជាក់លាក់ដល់សហគ្រិនវ័យក្មេង និងសហគ្រិនស្ត្រី ឬក្រុមងាយរងគ្រោះតាមរយៈកម្មវិធីអភិវឌ្ឍសហគ្រិនភាព បណ្តាញសហគ្រិនស្ត្រី និងកម្មវិធី Soft Loan ឬ Matching Grant ដែលមានអត្រាការប្រាក់ទាប និងលក្ខខណ្ឌបង់សងដែលមានភាពបត់បែន ដើម្បីជំរុញការចាប់ផ្តើម ច្នៃប្រតិដ្ឋ និងពង្រីកធុរកិច្ចប្រកបដោយចីរភាព។

១០. ពិនិត្យលទ្ធភាពផ្តល់វិភាជន៍កញ្ចប់ថវិកាជូនធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បន្ថែមទៀត ដើម្បីបង្កលក្ខណៈងាយស្រួល

ដល់សហគ្រាសក្នុងស្រុក ក្នុងការទទួលបានកម្ចី ក្នុងទំហំសមស្រប និងសម្រាប់រយៈពេលវែងជាងមុន។

### ៤.១.៤.៣. ការជំរុញហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់គាំទ្រដល់ ស.ម.ត.ម.

ការជំរុញអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ នឹងផ្តោតលើការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារការងារ និងការលើកកម្ពស់សន្តិសុខសង្គម និងលក្ខខណ្ឌការងារ ដើម្បីលើកកម្ពស់ផលិតភាព និងនវានុវត្តន៍ ក៏ដូចជាបង្កើតតម្រូវការទីផ្សារ ដើម្បីជំរុញគាំទ្រដល់ ស.ម.ត.ម. ឱ្យមានសមត្ថភាពខ្ពស់ ក្នុងការបង្កើតការងារ លើកកម្ពស់ផលិតផលក្នុងស្រុក ក៏ដូចជាលើកកម្ពស់សេដ្ឋកិច្ចក្នុងស្រុក។ ក្នុងន័យនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. រៀបចំវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគុណភាព ការកែច្នៃប្រកបដោយនវានុវត្តន៍ និងការវេចខ្ចប់សម្រាប់ ស.ម.ត.ម.។

២. ជំរុញការបណ្តុះបណ្តាលដល់ ស.ម.ត.ម. លើជំនាញបច្ចេកទេស ការគ្រប់គ្រងគុណភាព ជំនាញឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំនាញបៃតង និងបច្ចេកវិទ្យាបៃតង ដោយប្រើប្រាស់យន្តការដែលមានស្រាប់ រួមមានមូលនិធិអភិវឌ្ឍន៍ជំនាញ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និង សហគ្រិនខ្មែរ។

៣. បង្កើតមជ្ឈមណ្ឌលជាតិភ្ញាស់ ស.ម.ត.ម. (MSME Incubation Center)។

៤. សិក្សា និងរៀបចំយន្តការសម្រួលដល់ ស.ម.ត.ម. ចូលរួមផ្គត់ផ្គង់ទំនិញ និងសេវាកម្មដល់ស្ថាប័នសាធារណៈ តាមរយៈការផ្តល់កូតាទិញរបស់រដ្ឋសម្រាប់ ស.ម.ត.ម.។

៥. ជំរុញការអភិវឌ្ឍជំនាញ និងសមត្ថភាពកម្លាំងពលកម្ម តាមរយៈការបង្កើនជំនាញ (Upskilling) ការផ្លាស់ប្តូរជំនាញ (Reskilling) ការរៀនសូត្រពេញមួយជីវិត ការបណ្តុះបណ្តាលជំនាញគ្រប់កម្រិតសម្រាប់ម្ចាស់សហគ្រាស និងកម្មករនិយោជិត ព្រមទាំងការពង្រីកការវាយតម្លៃ និងការទទួលស្គាល់ជំនាញ តាមរយៈប្រព័ន្ធផ្តល់វិញ្ញាបនបត្រ និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សាដែលមានពីមុន (Recognition of Prior Learning)។

៦. ពង្រឹងភាពជាដៃគូរវាង ស.ម.ត.ម. និងគ្រឹះស្ថាន អ.ប.វ. តាមរយៈការបណ្តុះបណ្តាលនៅកន្លែងការងារ(Work-based Learning) ការហ្វឹកហ្វឺនកូនជាង ការហាត់ការ និងការបណ្តុះបណ្តាលតាមប្រព័ន្ធឆ្លាស់ (Dual Training) ដើម្បីជានាថាកម្មវិធីបណ្តុះបណ្តាលឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ទីផ្សារការងារ និងតម្រូវការរបស់សហគ្រាស។

៧. ពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារការងារ និងការព្យាករតម្រូវការជំនាញ តាមរយៈការពង្រឹងយន្តការប្រមូល ការវិភាគ និងផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារការងារ ទន្ទឹមនឹងការអភិវឌ្ឍយន្តការព្យាករណ៍តម្រូវការជំនាញ និងមុខរបរអាទិភាពសម្រាប់ ស.ម.ត.ម. ដើម្បីជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញប្រកប

ដោយប្រសិទ្ធភាពខ្ពស់។

៨. ពង្រីកវិសាលភាពគ្របដណ្តប់នៃរបបសន្តិសុខសង្គម និងលើកកម្ពស់លក្ខខណ្ឌការងារសម្រាប់ ស.ម.ត.ម. សំដៅបង្កើនភាពធន់របស់សហគ្រាស ពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងទំនាក់ទំនងវិជ្ជាជីវៈ រក្សាកម្លាំងពលកម្ម លើកកម្ពស់សុខុមាលភាពកម្មករនិយោជិត បង្កើនផលិតភាព កាត់បន្ថយអត្រាផ្លាស់ប្តូរការងារ ឬឈប់ពីការងារ និងជំរុញការធ្វើអន្តរកាលចូលក្នុងប្រព័ន្ធ។

## ៤.២. ផែនការសកម្មភាពគន្លឹះ

ដើម្បីជានាសម្រេចបានចក្ខុវិស័យ និងវិធានការខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់សកម្មភាពគន្លឹះសំខាន់ៗ តាមវិស័យ និងបានកំណត់ក្រសួង ស្ថាប័នដឹកនាំ សម្របសម្រួល និងចូលរួមទទួលខុសត្រូវ ដូចមានលម្អិតក្នុង ឧបសម្ព័ន្ធទី១ នៃយុទ្ធសាស្ត្រនេះ។ សកម្មភាពគន្លឹះនីមួយៗត្រូវមានផែនការសកម្មភាពជាក់លាក់ ដើម្បីអមជាមួយយុទ្ធសាស្ត្រជាតិនេះ។ លទ្ធផលដែលកើតចេញពីការអនុវត្តផែនការសកម្មភាពនេះ ត្រូវមានលក្ខណៈអាចវាស់វែងបាន និងមានភ្ជាប់មកជាមួយនូវការប៉ាន់ស្មានទំហំថវិកាដែលត្រូវការ។

ជាមួយគ្នានេះ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវដាក់ចេញនូវផែនការសកម្មភាពលម្អិតតាមវិស័យរៀងៗខ្លួន ដើម្បីចូលរួមចំណែកអនុវត្តវិធានការ និងសកម្មភាពគន្លឹះនៃយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ និងផ្លែផ្កា។

# ផ្នែកទី៥
# ការគ្រប់គ្រងហានិភ័យកម្ពុជា

ដើម្បីធានា ស.ម.ត.ម. អាចទប់ទល់នឹងហានិភ័យ និងបន្តអភិវឌ្ឍបានប្រកបដោយចីរភាព ចាំបាច់ត្រូវតែបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យជាផ្លូវការ ដែលអាចតាមដាន ព្យាករ និងឆ្លើយតបនឹងហានិភ័យបានទាន់ពេល។ ប្រព័ន្ធគ្រប់គ្រងហានិភ័យសម្រាប់ ស.ម.ត.ម. នេះ រួមមានការអភិវឌ្ឍប្រព័ន្ធព្រមានជាមុន (Early Warning System) ដោយប្រើប្រាស់ការវិភាគទិន្នន័យ និងប្រព័ន្ធវិភាគវៃឆ្លាតក្នុងទីផ្សារ (Market Intelligence) ដើម្បីព្យាករហានិភ័យសេដ្ឋកិច្ច ការបង្កើតមូលដ្ឋានទិន្នន័យសម្រាប់ហានិភ័យ (Risk Database) ដើម្បីប្រមូលព័ត៌មានអំពីហានិភ័យផ្នែកហិរញ្ញវត្ថុ បច្ចេកវិទ្យា បរិស្ថាន និងទីផ្សារ និងការពង្រឹងសមត្ថភាព តាមរយៈការបណ្តុះបណ្តាល ស.ម.ត.ម. លើការវាយតម្លៃហានិភ័យ និងការរៀបចំផែនការបន្តអាជីវកម្ម។ ចំពោះមុខ ហានិភ័យធំៗមានចំនួន ៣ ដូចខាងក្រោម៖

- **ហានិភ័យផ្ទៃក្នុងរបស់ ស.ម.ត.ម.៖** ការគ្រប់គ្រងមិនមានប្រសិទ្ធភាព កង្វះបុគ្គលិកជំនាញ កង្វះទុនក្នុងការដំណើរការ ការគ្រប់គ្រងបញ្ជីគណនេយ្យមិនត្រឹមត្រូវ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន និងគុណភាពផលិតផលមិនស្របតាមលក្ខខណ្ឌទីផ្សារ គឺជាហានិភ័យផ្ទៃក្នុងដែលអាចបណ្តាលឱ្យមានផលិតភាពទាប បាត់បង់ឱកាសទីផ្សារ ពិបាកទទួលបានឥណទានពីធនាគារ និងការរាំងស្ទះដល់ការនាំចេញ។ វិធានការកាត់បន្ថយរួមមានការបណ្តុះបណ្តាលតាមមជ្ឈមណ្ឌលបណ្តុះបណ្តាល ស.ម.ត.ម. និងកម្មវិធីបណ្តុះបណ្តាលនានា ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធឌីជីថល (Digital HR) និងកម្មវិធីគណនេយ្យ (Accounting Software) ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ និងការគាំទ្រដល់ការទទួលបាននូវវិញ្ញាបនបត្រផលិតផល ឬសេវា អនុលោមទៅតាមស្តង់ដាជាតិសម្រាប់ផលិតផល ឬទទួលបាននូវវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងគុណភាព ដូចជា CS ISO 9001 ឬវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ដូចជា CS HACCP, CS ISO 22000 អនុលោមទៅតាមស្តង់ដាជាតិសម្រាប់ប្រព័ន្ធគ្រប់គ្រងផលិតកម្ម និងសេវាកម្ម តាមរយៈវិទ្យាស្ថានស្តង់ដាកម្ពុជា មន្ទីរពិសោធន៍ និងប្រព័ន្ធទំនាក់ទំនងសាធារណៈ។
- **ហានិភ័យក្រៅប្រទេស៖** កត្តាខាងក្រៅរួមមានការផ្លាស់ប្តូរទីផ្សារអន្តរជាតិ ការប្រែប្រួលអត្រាប្តូរប្រាក់ ភាពស្មុគស្មាញនិងមិនច្បាស់លាស់នៃស្ថានភាពសេដ្ឋកិច្ចពិភពលោក បញ្ហាអាកាសធាតុ និងបរិស្ថាន ព្រមទាំងហានិភ័យផ្នែកសន្តិសុខសាយប័រ (Cybersecurity) ទាំងនេះអាចបង្កឱ្យខាតបង់ចំណូល និងបាត់បង់ទីផ្សារសកល ថ្លៃផលិតផលឬវត្ថុធាតុដើមកើនឡើង បាត់បង់សមត្ថភាពប្រកួតប្រជែង ខូចខាតទិន្នផល និងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះអាជីវកម្ម។ វិធានការកាត់បន្ថយរួមមានការធ្វើពិពិធកម្មមុខទំនិញនិងទីផ្សារ ការប្រើប្រាស់ប្រព័ន្ធវិភាគវៃឆ្លាតក្នុងទីផ្សារ (Market Intelligence Tools) ការបង្កើតយន្តការផ្តល់ព័ត៌មានអំពីហានិភ័យ ការផ្តល់ធានារ៉ាប់រងហិរញ្ញវត្ថុ ការអនុវត្តកសិកម្មឆ្លាតវៃ (Climate-smart Agriculture) ការប្រើហិរញ្ញវត្ថុបៃតង (Green Finance) និងធានារ៉ាប់រងកសិកម្ម (Agricultural Insurance) ព្រមទាំងការពង្រឹងសុវត្ថិភាពឌីជីថល។

- **ហានិភ័យប្រព័ន្ធគ្រប់គ្រង៖** បញ្ហាប្រព័ន្ធគ្រប់គ្រងកើតឡើងពីកង្វះប្រព័ន្ធតាមដាន និងទិន្នន័យសម្រាប់ធ្វើការវិភាគ និងវាយតម្លៃហានិភ័យ ដែលធ្វើឱ្យស្ថាប័នមិនទទួលព័ត៌មាននៃការព្រមានជាមុន មុនពេលដែលហានិភ័យកើតមានឡើង និងមិនអាចឆ្លើយតបបានទាន់ពេលវេលា។ ហានិភ័យប្រភេទនេះអាចកាត់បន្ថយបានតាមរយៈការបង្កើតអង្គភាពត្រួតពិនិត្យហានិភ័យ ការអភិវឌ្ឍប្រព័ន្ធព្រមានជាមុន ការពង្រឹងការសម្រេចចិត្តផ្អែកលើទិន្នន័យ និងការបង្កើតមូលនិធិជំនួយក្នុងពេលមានវិបត្តិ ដើម្បីធានាការឆ្លើយតបមានប្រសិទ្ធភាព និងទាន់ពេលវេលា។

# ផ្នែកទី៦
# យន្តការស្ថាប័ន និងការតាមដាន និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តយុទ្ធសាស្ត្រជាតិនេះសម្រេចបានផ្លែផ្កា និងប្រកបដោយភាពជោគជ័យ ទាមទារឱ្យមានការកំណត់នូវតួនាទីនិងភារកិច្ចរបស់ក្រសួង ស្ថាប័ន ស្របតាមអភិក្រម «ជវភាពនៃប្រព័ន្ធតួអង្គតែមួយ» ដែលសំដៅដល់ការសហការ ការចូលរួម និងការអនុវត្តការងារនេះរួមគ្នា ប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម។ ក្នុងន័យនេះ តួនាទី និងភារកិច្ចបានកំណត់តួអង្គសំខាន់ៗ រួមមានគណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម (គ.ស.ម.ត.ម.) ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត និងវិស័យឯកជន ដែលត្រូវសហការគ្នា ប្រមូលផ្តុំផ្ទៀងផ្ទាត់ និងបូកសរុបវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ធានាសម្រេចបាននូវចំណុចដៅនៃសូចនាករសមិទ្ធកម្មគន្លឹះដែលបានកំណត់ក្នុងក្របខ័ណ្ឌនេះផង និងធ្វើឱ្យប្រសើរឡើងនូវការផ្សារភ្ជាប់រវាងគោលនយោបាយយុទ្ធសាស្ត្រផែនការសកម្មភាពតាមវិស័យ និងផែនការយុទ្ធសាស្ត្រនានាជាដើម។

## ៦.១. ការរៀបចំក្របខ័ណ្ឌស្ថាប័ន និងយន្តការសម្របសម្រួល

### ៦.១.១. គណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម (គ.ស.ម.ត.ម.)

ដើម្បីដឹកនាំ និងសម្របសម្រួលដល់ការអនុវត្តយុទ្ធសាស្ត្រជាតិនេះ រាជរដ្ឋាភិបាលនឹងបង្កើតគណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម (គ.ស.ម.ត.ម.) ក្រោមឆត្រគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) ដោយកែសម្រួលយន្តការគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ដែលមានស្រាប់ និងត្រូវបានបង្កើតឡើងនៅឆ្នាំ២០២០ ស្របតាមអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០។ គ.ស.ម.ត.ម. មានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- អនុម័តសូចនាករសមិទ្ធកម្មគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០
- ដឹកនាំ សម្របសម្រួល និងដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរស្ថាប័ន ដើម្បីអភិវឌ្ឍ ស.ម.ត.ម.
- សម្របសម្រួលក្នុងកម្រិតគោលនយោបាយនូវកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍ លើការងារជំរុញការអភិវឌ្ឍ ស.ម.ត.ម. នៅកម្ពុជា
- ដឹកនាំ រៀបចំ និងស្នើឡើងសកម្មភាពគោលនយោបាយ និងយុទ្ធសាស្ត្រ ជូនរាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេច ដើម្បីបន្តលើកស្ទួយ ស.ម.ត.ម. តាមតម្រូវការចាំបាច់
- រៀបចំកិច្ចប្រជុំរៀងរាល់មួយឆ្នាំម្តងយ៉ាងតិច ដើម្បីពិនិត្យលើស្ថានភាព វឌ្ឍនភាព និងបញ្ហាប្រឈមផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រជាតិ និងបញ្ហាពាក់ព័ន្ធផ្សេងៗ
- សម្របសម្រួលក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ស្តីពីវឌ្ឍនភាព និងបញ្ហា

ប្រឈមក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិនេះ ដោយផ្អែកលើគោលដៅ និងសូចនាករដែលបានកំណត់ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំវិធានការចាំបាច់ ក្នុងការដោះស្រាយបញ្ហាចំពោះមុខ ដែលកើតឡើងក្នុងពេលអនុវត្ត។

គ.ស.ម.ត.ម. ដឹកនាំដោយឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកមួយរូប និងមានអនុប្រធានចំនួន ៣ រូប ក្នុងនោះ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាអនុប្រធានអចិន្ត្រៃយ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាអនុប្រធាន ព្រមទាំងមានរដ្ឋមន្ត្រី និងប្រធានក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិក។ សមាសភាពជាក់ស្តែងនៃ គ.ស.ម.ត.ម. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា។

គ.ស.ម.ត.ម. អាចមានអនុគណៈកម្មាធិការ ឬក្រុមការងារបច្ចេកទេសផ្សេងៗ ដើម្បីបំពេញភារកិច្ចដូចមានកំណត់ខាងលើ តាមតម្រូវការចាំបាច់។ គ.ស.ម.ត.ម. មានលេខាធិការដ្ឋានមួយ ដែលជាសេនាធិការក្នុងការងារសម្របសម្រួលរួម លើការអនុវត្តយុទ្ធសាស្ត្រនេះ និងការងារពាក់ព័ន្ធផ្សេងៗ។

### ៦.១.២. លេខាធិការដ្ឋាន នៃ គ.ស.ម.ត.ម.

លេខាធិការដ្ឋានដឹកនាំដោយប្រធានមួយរូប ដែលមានសមាសភាពជារដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមានអនុប្រធានចំនួន ៣ រូប ដែលមានសមាសភាពជារដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម និងមានរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ជាសមាជិក។ សមាសភាព តួនាទី និងភារកិច្ចនៃលេខាធិការដ្ឋាននៃ គ.ស.ម.ត.ម. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ស.ម.ត.ម.។

ក្នុងនាមជាអង្គភាពដឹកនាំសម្របសម្រួលរួមលើការអនុវត្តក្របខ័ណ្ឌនេះ លេខាធិការដ្ឋាននៃ គ.ស.ម.ត.ម. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជាសេនាធិការរបស់ គ.ស.ម.ត.ម. លើការតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិនេះ
- ដឹកនាំ រៀបចំ និងកសាងប្រព័ន្ធតាមដាន និងវាយតម្លៃ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធ នឹងការតាមដាន និងវាយតម្លៃ
- ដឹកនាំរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់ដំណើរការតាមដាន និងវាយតម្លៃ
- ដឹកនាំនិងតម្រង់ទិសនិងសម្របសម្រួលជាមួយក្រសួងស្ថាប័នក្នុងការរៀបចំទិន្នន័យស្ថិតិពាក់ព័ន្ធក្នុងការអនុវត្តក្របខ័ណ្ឌនេះ
- ដឹកនាំ សម្រេច និងសម្របសម្រួលលើការបណ្តុះបណ្តាលសមត្ថភាព និងផែនការវាយតម្លៃជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ លើការអនុវត្តយុទ្ធសាស្ត្រនេះ
- ពិនិត្យ លើកសំណើ និងរាយការណ៍តាមកាលកំណត់ជាក់លាក់ និងមានការបត់បែនតាមការជាក់ស្តែង ជូនរាជរដ្ឋាភិបាល

- ជំរុញក្រសួង ស្ថាប័ន ដើម្បីដោះស្រាយកិច្ចការអាទិភាពដែលមានភាពយឺតយ៉ាវ ឬមានវឌ្ឍនភាពតិចតួច ក្នុងករណីបញ្ហាប្រឈមគន្លឹះមានលក្ខណៈកែទម្រង់ និងយុទ្ធសាស្ត្រ ដែលចាំបាច់ត្រូវការដោះស្រាយកម្រិតគោលនយោបាយ ត្រូវរាយការណ៍ជូន គ.ស.ម.ត.ម. ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ផ្តល់អនុសាសន៍ និងតម្រង់ទិសលើការកែសម្រួលគោលនយោបាយ និងយុទ្ធសាស្ត្រជាតិតាមវិស័យ ការកែសម្រួលផែនការ និងការកែសម្រួលយន្តការអនុវត្ត និងស្នើសុំការសម្រេចពី គ.ស.ម.ត.ម.
- ធានានូវគុណភាពនៃការវាយតម្លៃ តាមរយៈការពិនិត្យលើអនុលោមភាពនៃដំណើរការនៃការវាយតម្លៃទៅតាមនិយាម ស្តង់ដា និងនីតិវិធីនៃការវាយតម្លៃដែលបានដាក់ចេញ
- រៀបចំកិច្ចប្រជុំពិនិត្យវឌ្ឍនភាពលើការងាររបស់លេខាធិការដ្ឋាន រៀងរាល់ ៣ ខែម្តង
- ត្រួតពិនិត្យលើការរៀបចំផែនការការវាយតម្លៃ ព្រមទាំងកៀរគរធនធានចាំបាច់នានា ដែលរួមទាំងធនធានមនុស្ស ថវិកា និងសម្ភារៈ សម្រាប់អនុវត្តផែនការវាយតម្លៃឱ្យប្រកបទៅដោយ ប្រសិទ្ធភាពខ្ពស់
- រៀបចំ និងស្នើឡើងនូវគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការតាមដាន និងវាយតម្លៃយុទ្ធសាស្ត្រជាតិ ជូន គ.ស.ម.ត.ម. ពិនិត្យ និងសម្រេច។

### ៦.១.៣. ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត

១. **ក្រសួង ឧ.វ.ប.ន.៖** ដឹកនាំ និងសម្របសម្រួលយុទ្ធសាស្ត្រជាតិ និងរៀបចំផែនការអនុវត្តប្រចាំឆ្នាំ និងធ្វើរបាយការណ៍ជូន គ.ស.ម.ត.ម. និងជូនប្រមុខរាជរដ្ឋាភិបាល។

២. **ក្រសួងពាណិជ្ជកម្ម៖** អភិវឌ្ឍទីផ្សារ ក្នុង និងក្រៅប្រទេស និងដឹកនាំកម្មវិធី Digital Trade និង E-commerce Platforms។

៣. **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖** ផ្តល់ការឧបត្ថម្ភហិរញ្ញវត្ថុ និងជំរុញឱ្យមានការចូលរួមក្នុងឧបករណ៍ហិរញ្ញវត្ថុថ្មី និងគ្រប់គ្រង និងគាំទ្រពន្ធដារ និងអនុគ្រោះពន្ធសម្រាប់ ស.ម.ត.ម.។

៤. **ក្រសួងអប់រំ យុវជន និងកីឡា** និង **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ភ្ជាប់កម្មវិធីអប់រំជាមួយតម្រូវការការងារ និងបណ្តុះបណ្តាលកម្លាំងពលកម្ម និងជំនាញឌីជីថល/បៃតង។

៥. **ធនាគារជាតិនៃកម្ពុជា** និង **ស្ថាប័នហិរញ្ញវត្ថុ៖** គាំទ្រការចូលប្រើប្រាស់ឥណទាន បង្កើតប្រព័ន្ធធានារ៉ាប់រងហិរញ្ញវត្ថុ និងប្រើប្រាស់ Fintech សមាគមឯកជន និងឧស្សាហកម្មផ្តល់ Feedback ពី ស.ម.ត.ម. និងជាដៃគូសំខាន់ក្នុង Public-Private Dialogue។

៦. **ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរ៉ែ និងថាមពល** និង **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍៖** អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ ស.ម.ត.ម. ដូចជា ផ្លូវ អគ្គិសនី និងបណ្តាញទូរគមនាគមន៍ ព្រមទាំងចូលរួមកាត់បន្ថយថ្លៃដើមក្នុងប្រតិបត្តិការរបស់ស.ម.ត.ម.។

៧. **ក្រសួង ស្ថាប័នពាក់ព័ន្ធ៖** ជំរុញការអនុវត្តការងារ ស.ម.ត.ម.តាមវិស័យរៀងៗខ្លួន។

### ៦.១.៤. ធនធានសម្រាប់អនុវត្តយុទ្ធសាស្ត្រ

ប្រភពធនធានសម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិនេះ រួមមានថវិការដ្ឋ ធនធានទទួលបានពីអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងប្រភពស្របច្បាប់ផ្សេងៗទៀត។ ទន្ទឹមនេះ ក្រសួងស្ថាប័នត្រូវសន្សំសំចៃធនធាន (មនុស្ស និងហិរញ្ញវត្ថុ) ក្នុងក្របខ័ណ្ឌនិងយន្តការមានស្រាប់របស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវផែនការសកម្មភាពគន្លឹះ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមចំណែកក្នុងកិច្ចការកែទម្រង់ផ្សេងៗស្របតាមឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ដែលរួមមានការកាត់បន្ថយនីតិវិធីរដ្ឋបាលនានា ព្រមទាំងទទួលយកនូវផលប៉ះពាល់មួយចំនួន ដើម្បីការអភិវឌ្ឍ ស.ម.ត.ម.អាចប្រព្រឹត្តទៅបានលឿនរហ័ស រឹងមាំប្រកបដោយចីរភាព ភាពធន់ និងជានាអធិបតេយ្យភាពនៃសេដ្ឋកិច្ចជាតិ។

## ៦.២. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិ

### ៦.២.១. យន្តការតាមដាន និងត្រួតពិនិត្យ

#### ៦.២.១.១. និយមន័យ និងវិសាលភាព

ការតាមដាន និងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រជាតិ គឺជាមុខងារគ្រប់គ្រងដែលពាក់ព័ន្ធនឹងដំណើរការនៃការប្រមូល និងចងក្រងសមិទ្ធកម្ម ឬលទ្ធផលជាក់ស្តែងនៃការអនុវត្តផែនការសកម្មភាព ដើម្បីសម្រេចឱ្យបាននូវផែនការសកម្មភាព ដែលត្រូវបានចូលរួមអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ការតាមដានរបាយការណ៍វឌ្ឍនភាព និងការចុះពិនិត្យដល់ទីកន្លែង ព្រមទាំងកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់អំពីវឌ្ឍនភាពនៃការអនុវត្ត ផ្ទៀងផ្ទាត់ និងផ្តល់សុពលភាព ឬស្វែងរកមូលហេតុ និងកស្តុតាងឱ្យបានច្បាស់លាស់ ក្នុងករណីដែលការអនុវត្តមិនសម្រេចតាមការគ្រោងទុក ឬវឌ្ឍនភាពយឺតយ៉ាវ។ ឈរលើលទ្ធផលនៃការតាមដាននេះ ការជូនដំណឹង ឬស្នើឡើងនូវអនុសាសន៍ជូនដល់ថ្នាក់ដឹកនាំអំពីវឌ្ឍនភាពយឺតយ៉ាវ ត្រូវអនុវត្តជាបន្ទាន់ សំដៅចាត់វិធានការ ឬយុទ្ធសាស្ត្រអន្តរាគមន៍នានា និងកែសម្រួលការអនុវត្តផែនការសកម្មភាពនានាក្នុងការសម្រេចបាននូវលទ្ធផលដែលបានកំណត់ឱ្យបានទាន់ពេល និងប្រសិទ្ធភាព។

ការតាមដាននឹងត្រូវវាស់វែងនូវកិច្ចការដែលសម្រេចបានពាក់ព័ន្ធនឹងផែនការសកម្មភាពជាក់លាក់ ជាពិសេសផ្តោតជាសំខាន់ទៅលើវឌ្ឍនភាពនៃការអនុវត្តនៃយុទ្ធសាស្ត្រជាតិ ដែលមានលទ្ធផលសម្រេចបានក្នុងឆ្នាំនីមួយៗ។

#### ៦.២.១.២. វិធីសាស្ត្រតាមដាន

លេខាធិការដ្ឋាន នៃ គ.ស.ម.ត.ម. ប្រើប្រាស់វិធីសាស្ត្រសម្រាប់ការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពនានា ដែលមានដូចជា៖ (១) ការពិនិត្យលើរបាយការណ៍វឌ្ឍនភាព (២) ការចុះពិនិត្យផ្ទៀងផ្ទាត់ដល់ទីកន្លែង និង (៣) ការរៀបចំកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់។ បន្ថែមលើនេះ លេខាធិការដ្ឋានតាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិ ក៏នឹងរៀបចំ និងប្រើប្រាស់ប្រព័ន្ធរាយការណ៍និងតាមដាន ដែលមានប្រព័ន្ធព័ត៌មាន (Dashboard) ដើម្បីបង្ហាញអំពីវឌ្ឍនភាពនៃការអនុវត្ត

ផែនការសកម្មភាព សម្រាប់រៀបចំលទ្ធផល ឬរបាយការណ៍វឌ្ឍនភាព ជូនរាជរដ្ឋាភិបាលពិនិត្យ និងផ្តល់អនុសាសន៍។

តារាងទី ៣៖ វិធីសាស្ត្រសម្រាប់ការតាមដាន

| ប្រភេទវិធីសាស្ត្រ | ការប្រើប្រាស់ |
|---|---|
| ការពិនិត្យរបាយការណ៍ | • ការពិនិត្យរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រជាតិ ដែលត្រូវរៀបចំឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ទទួលបន្ទុកអនុវត្តយុទ្ធសាស្ត្រជាតិនេះ។<br>• ត្រូវរាយការណ៍ និងរៀបចំរបាយការណ៍តាមដាន និងត្រួតពិនិត្យ ដោយបង្ហាញអំពីវឌ្ឍនភាពសំខាន់ៗ កំណត់បញ្ហាប្រឈម លើកអនុសាសន៍ និងដំណោះស្រាយនៅក្នុងរបាយការណ៍តាមដាន និងត្រួតពិនិត្យ។ |
| ការចុះពិនិត្យដល់ទីកន្លែង | • ការចុះពិនិត្យដល់ទីកន្លែងត្រូវអនុវត្តតាមរយៈ៖ ១)- ការណែនាំរបស់រាជរដ្ឋាភិបាល និង ២)- ការលើកសំណើជូនរាជរដ្ឋាភិបាលដោយ គ.ស.ម.ត.ម. ពិនិត្យ និងសម្រេច។ |
| កិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ | • កិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ត្រូវរៀបចំជាមួយ ១)- ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត និង ២)- ត្រូវមានកិច្ចប្រជុំផ្ទៃក្នុងលេខាធិការដ្ឋាន គ.ស.ម.ត.ម. ដើម្បីផ្ទៀងផ្ទាត់ ជាពិសេសក្នុងករណីវឌ្ឍនភាពគន្លឹះមិនសម្រេចបាន ឬមានភាពយឺតយ៉ាវ។<br>• ក្នុងករណីចាំបាច់ លេខាធិការដ្ឋាន គ.ស.ម.ត.ម. អាចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ ឬភាគីពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលបន្ថែម។ |

### ៦.២.១.៣. ដំណើរការនៃក្របខ័ណ្ឌការងារតាមដាន និងត្រួតពិនិត្យ

ក្របខ័ណ្ឌរាយការណ៍តាមដាន និងត្រួតពិនិត្យនេះ បានកំណត់វិហរនៃការរាយការណ៍វឌ្ឍនភាព និងកាតព្វកិច្ចរបស់ គ.ស.ម.ត.ម. ក្រុមការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដែលទទួលបន្ទុកដឹកនាំការអនុវត្ត និងចូលរួមអនុវត្ត ត្រូវសម្របសម្រួល រៀបចំ និងផ្តល់ព័ត៌មានស្ថិតិនិងទិន្នន័យ ទៅតាមពេលវេលា ដែលបានកំណត់ក្នុងក្របខ័ណ្ឌនេះ។

រំហូរនៃការរាយការណ៍វឌ្ឍនភាពតាម គ.ស.ម.ត.ម. ក្រុមការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបានកំណត់ និងដំណើរការដូចខាងក្រោម៖

ក) ក្រសួង ស្ថាប័នទទួលបន្ទុកដឹកនាំ និងចូលរួមអនុវត្ត ដែលមានកំណត់ការវាស់វែងសមិទ្ធកម្ម ត្រូវផ្ទៀងផ្ទាត់ និងបូកសរុបលើព័ត៌មានស្ថិតិ និងទិន្នន័យ សម្រាប់រាយការណ៍វឌ្ឍនភាព។

ខ) លេខាធិការដ្ឋាននៃ គ.ស.ម.ត.ម. ត្រូវរៀបចំរបាយការណ៍តាមដាន និងត្រួតពិនិត្យ និងលើកអនុសាសន៍នានា ព្រមទាំងរាយការណ៍លទ្ធផលនៃការបូកសរុប និងវាយតម្លៃជូន **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យសម្រេច។ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** អាចពិនិត្យលើវឌ្ឍនភាពតាមរយៈប្រព័ន្ធបង្ហាញព័ត៌មាន (Dashboard)។

### ៦.២.១.៤. ក្របខ័ណ្ឌពេលវេលានៃការរាយការណ៍

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលចូលរួមអនុវត្តក្របខ័ណ្ឌនេះ ត្រូវអនុវត្តទៅតាមពេលវេលានៃការរាយការណ៍ ដែលត្រូវបានកំណត់ ដូចខាងក្រោម៖

- របាយការណ៍តាមដាន និងត្រួតពិនិត្យប្រចាំឆមាស ត្រូវរាយការណ៍ ***យ៉ាងយូរ១ខែ*** ក្រោយការបញ្ចប់ឆមាសនីមួយៗ
- របាយការណ៍តាមដាន និងត្រួតពិនិត្យប្រចាំឆ្នាំត្រូវរាយការណ៍ ***យ៉ាងយូរ២ខែ*** ក្រោយការបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ
- របាយការណ៍ពាក់កណ្ដាលអាណត្តិ ត្រូវរាយការណ៍នៅ ***ត្រឹមត្រីមាសទី២ ឆ្នាំ២០២៨***
- រាយការណ៍ចុងអាណត្តិ ត្រូវរាយការណ៍នៅ ***ត្រឹមត្រីមាសទី២ ឆ្នាំ២០៣០*** ។

លេខាធិការដ្ឋាននៃ គ.ស.ម.ត.ម. ត្រូវរៀបចំរបាយការណ៍នីមួយៗ តាមរយៈក្របខ័ណ្ឌពេលវេលាដែលបានកំណត់ ដូចខាងក្រោម៖

- ត្រូវបញ្ចប់របាយការណ៍តាមដាន និងត្រួតពិនិត្យប្រចាំឆមាសយ៉ាងយូរ១ខែ បន្ទាប់ពីទទួលបានរបាយការណ៍តាមដាន និងត្រួតពិនិត្យប្រចាំឆមាស ពីក្រសួង ស្ថាប័នពាក់ព័ន្ធ
- ត្រូវបញ្ចប់របាយការណ៍តាមដាន និងត្រួតពិនិត្យប្រចាំឆ្នាំយ៉ាងយូរ២ខែ បន្ទាប់ពីទទួលបានរបាយការណ៍តាមដាន និងត្រួតពិនិត្យប្រចាំឆ្នាំ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ
- ត្រូវបញ្ចប់របាយការណ៍ចុងអាណត្តិ យ៉ាងយូរ៣ខែ បន្ទាប់ពីទទួលបានរបាយការណ៍តាមដាន និងត្រួតពិនិត្យចុងអាណត្តិ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ៦.២.២. យន្តការវាយតម្លៃ

ការវាយតម្លៃគឺជាការពិនិត្យវិនិច្ឆ័យដោយផ្អែកលើភស្តុតាង ដោយធ្វើការវិភាគស៊ីជម្រៅ ស្វែងរកហេតុផលនៃការអនុវត្តយុទ្ធសាស្ត្រជាតិ ព្រមទាំងគិតគូរលើទិដ្ឋភាពមួយចំនួន ដូចជាភាពមានប្រយោជន៍ សិនិទ្ធភាព សមានគតិភាព ស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព កម្មវិបាក និងចីរភាព។ ការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិត្រូវបានកំណត់ជា២ប្រភេទរួមមាន៖ ការវាយតម្លៃពាក់កណ្ដាលនិងចុងអាណត្តិនៃយុទ្ធសាស្ត្រ និងការវាយតម្លៃបន្ទាន់។

### ៦.២.២.១. ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងអាណត្តិនៃយុទ្ធសាស្ត្រជាតិ

ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងអាណត្តិយុទ្ធសាស្ត្រជាតិ ឆ្នាំ២០៣០ គឺជាការពិនិត្យគ្រប់ជ្រុងជ្រោយ និងធ្វើឡើងនៅពេលពាក់កណ្តាលអាណត្តិនៃយុទ្ធសាស្ត្រ ក្នុងឆ្នាំ២០២៨ និងចុងអាណត្តិនៃយុទ្ធសាស្ត្រ នៅឆ្នាំ២០៣០ ដែលមានគោលដៅ ដូចខាងក្រោម៖

ក. វាស់វែង និងពិនិត្យសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាព ធៀបទៅនឹងចំណុចដៅ និងគោលបំណងដែលបានកំណត់

ខ. ប្រមើលមើលនូវលទ្ធផល និងកម្មវិបាករយៈពេលមធ្យម និងវែង មកលើវឌ្ឍនភាព និងការផ្លាស់ប្តូរជារចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចកម្ពុជា

គ. ផ្តល់នូវបទពិសោធន៍ និងឧត្តមានុវត្តន៍នៃការអនុវត្តយុទ្ធសាស្ត្រជាតិ ដែលរួមទាំងភាពជោគជ័យ និងបញ្ហាប្រឈម ដើម្បីជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្រជាតិបន្ទាប់ទៀត ឱ្យកាន់តែគ្រប់ជ្រុងជ្រោយ។

### ៦.២.២.២. ការវាយតម្លៃបន្ទាន់

ការវាយតម្លៃបន្ទាន់គឺជាវិធីសាស្ត្រវាយតម្លៃលើបញ្ហាជាក់លាក់ ដែលលេចឡើងនៅក្នុងដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រជាតិនេះ សំដៅ៖ ១)- កំណត់ឱ្យបានឆាប់រហ័សនូវឫសគល់នៃបញ្ហា ដើម្បីចៀសវាងការជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរដល់ភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រជាតិនេះ និង ២)- ផ្តល់អនុសាសន៍កែលម្អ និងដោះស្រាយទាន់ពេលវេលា ដែលអាចឱ្យភាគីពាក់ព័ន្ធធ្វើការកែតម្រូវ និងតម្រង់ទិសក្នុងការអនុវត្ត។

ការវាយតម្លៃបន្ទាន់ផ្តោតទៅលើការដោះស្រាយបញ្ហាប្រឈមគន្លឹះ ដែលត្រូវបានកំណត់តាមរយៈរបាយការណ៍តាមដានលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព។ ការវាយតម្លៃបន្ទាន់នឹងត្រូវធ្វើឡើងដោយផ្អែកតាមការសម្រេចរបស់លេខាធិការដ្ឋានយុទ្ធសាស្ត្រជាតិ ឬក្រោមការណែនាំរបស់ គ.ស.ម.ត.ម.។ ជារួម ការវាយតម្លៃនេះនឹងផ្តោតលើការអនុវត្តយុទ្ធសាស្ត្រជាតិ ដែលមានភាពយឺតយ៉ាវ ឬមិនមានវឌ្ឍនភាព។

### ៦.២.២.៣. វិធីសាស្ត្រនៃការប្រមូលទិន្នន័យសម្រាប់ការវាយតម្លៃ

វិធីសាស្ត្រនៃការប្រមូលទិន្នន័យសម្រាប់ការវាយតម្លៃ មានដូចជា៖ ការពិនិត្យឯកសារ សម្ភាសន៍ ការពិភាក្សាជាក្រុម ករណីការសិក្សាស្វែងយល់ ការអង្កេតដោយផ្ទាល់ និងបេសកកម្មដល់ទីកន្លែងជាដើម។

# ផ្នែកទី៧
# សេចក្តីសន្និដ្ឋាន

ការជំរុញអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម មានសារៈសំខាន់សម្រាប់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលបានចូលរួមផ្តល់ការងារជូនប្រជាជនក្នុងរង្វង់ប្រមាណ ៧០% នៃកម្លាំងពលកម្មសរុប។ ដូច្នេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវ "**យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០**" ដែលឆ្លុះបញ្ចាំងពីទិសដៅប្រកបដោយយុទ្ធសាស្ត្រវែងឆ្ងាយ ក្នុងការធានាបាននូវចលនការកំណើនសេដ្ឋកិច្ចជាតិក្នុងរយៈពេលវែង ប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយពង្រឹងឧត្តមភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព និងសមត្ថភាពផលិតកម្ម។

យុទ្ធសាស្ត្រជាតិនេះនឹងរួមចំណែកដល់ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការធានាឱ្យបាននូវការបង្កើតការងារ សមធម៌ និងប្រសិទ្ធភាព ដូចមានរំលេចក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងរួមចំណែកសម្រេចបាននូវចក្ខុវិស័យរយៈពេលវែង ក្នុងការប្រែក្លាយកម្ពុជាជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ដើម្បីឱ្យពលរដ្ឋកម្ពុជាគ្រប់រូបមានស្ថិរភាពការងារ និងរស់នៅក្នុងជីវភាពសម្បូររុងរឿង និងសង្គមសុខដុម។ តាមរយៈយុទ្ធសាស្ត្រជាតិនេះ សហគ្រាសធុនមីក្រូ តូច និងមធ្យម នឹងមានឱកាស និងលទ្ធភាពទទួលបានការគាំទ្រទាំងក្នុងទិដ្ឋភាពហិរញ្ញវត្ថុ មិនមែនហិរញ្ញវត្ថុ បច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីកសាងមូលដ្ឋានសហគ្រាសឱ្យបានរឹងមាំ ពង្រឹងសមត្ថភាពផលិតកម្ម និងភាពប្រកួតប្រជែង ដើម្បីឈានទៅចាប់យកតម្លៃបន្ថែមខ្ពស់ ទាំងក្នុងទីផ្សារជាតិ និងអន្តរជាតិ។

យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០ នេះ នឹងផ្តោតលើយុទ្ធសាស្ត្រគន្លឹះចំនួន ៤ ដែលរួមមាន ១)- ការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់ ២)- ការលើកកម្ពស់សមត្ថភាពផលិតកម្ម សេវាកម្ម និងការចាប់យកបច្ចេកវិទ្យានិងនវានុវត្តន៍ ៣)- ការបង្កើនសមត្ថភាពប្រកួតប្រជែង ក្នុងទីផ្សារជាតិ និងអន្តរជាតិ និង ៤)- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។

ភាពជោគជ័យនៃយុទ្ធសាស្ត្រជាតិនេះជាភារកិច្ចរបស់អន្តរក្រសួង ស្ថាប័ន និងអន្តរវិស័យ ដែលទាមទារនូវឆន្ទៈនយោបាយមោះមុត និងការចូលរួមប្រកបដោយសហថាមពល និងកិច្ចសហការយ៉ាងស្អិតល្មួតរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរួមគ្នាគិត និងរួមគ្នាធ្វើ ប្រកបដោយស្មារតីទទួលខុសត្រូវស្របតាមអភិក្រម **«ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ»**។ រាជរដ្ឋាភិបាលនឹងរៀបចំបង្កើតគណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម (គ.ស.ម.ត.ម.) ជាយន្តការស្ថាប័ន ដែលមានសមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ សហការ និងរួមចំណែកជំរុញការអនុវត្តយុទ្ធសាស្ត្រជាតិនេះឱ្យបានជោគជ័យ។

យុទ្ធសាស្ត្រនេះជា «ឯកសាររស់» ដែលអាចនឹងត្រូវបានកែសម្រួលបន្ថែមជាយថាហេតុ ដើម្បីធានាបាននូវសង្គតិភាព និងភាពសមស្របទៅតាមការវិវត្តសង្គម-សេដ្ឋកិច្ចជាក់ស្តែង នៅក្នុងប្រទេស តំបន់ និងសកល ក៏ដូចជាស្របតាមវឌ្ឍនភាពនៃលទ្ធផល ដែលបានមកពីការអនុវត្តការតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រនេះ៕

# ឧបសម្ព័ន្ធទី១៖ តារាងផែនការសកម្មភាពគន្លឹះសម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ឆ្នាំ២០២៦-២០៣០

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| **យុទ្ធសាស្ត្រទី១. ការកែលម្អបរិស្ថានធុរកិច្ច និងនិយ័តកម្មផ្នែកច្បាប់** | | | |
| **១.១. ការកែលម្អបទប្បញ្ញត្តិនិងគតិយុត្តពាក់ព័ន្ធ** | | | |
| ១ | កំណត់លម្អិតនូវនិយមន័យ ស.ម.ត.ម. ឱ្យមានភាពច្បាស់លាស់ និងមានភាពជាក់ស្តែងនិយម ដែលអាចអនុវត្តសម្រាប់រាល់ក្រសួង ស្ថាប័ន ប្រកបដោយសង្គតិភាព។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០២៧ |
| ២ | រៀបចំយន្តការផ្តល់ការលើកទឹកចិត្ត ដល់ ស.ម.ត.ម. ជារួម ឬតាមវិស័យ ដោយផ្តោតលើការលើកទឹកចិត្តផ្នែកពន្ធដារ និងផ្នែកគយ ការកាត់បន្ថយ ឬសាមញ្ញកម្មបន្ទុកសារពើពន្ធផ្សេងទៀត ការសម្របសម្រួលលក្ខខណ្ឌធុរកិច្ច ការសម្រួលនីតិវិធីស្នើសុំឯកសារ និងការនាំចេញ នាំចូល និងការអនុគ្រោះពេល (Grace Period) សម្រាប់បំពេញអនុលោមភាពចុះបញ្ជី សំដៅជំរុញការចុះបញ្ជីផ្លូវការរបស់ ស.ម.ត.ម. និងផ្តល់ការគាំទ្រដល់ ស.ម.ត.ម. ដែលមានលទ្ធភាព និងសក្តានុពលពិតប្រាកដក្នុងការអភិវឌ្ឍសហគ្រាស។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០២៧ |
| ៣ | រៀបចំយន្តការជម្រះបញ្ជី ដើម្បីបិទសហគ្រាស ប្រកបដោយភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយធានាបាននូវភាពសាមញ្ញ និងប្រសិទ្ធភាព និងការពារការគេចវេសកាតព្វកិច្ចណាមួយ។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- អ.ព.ជ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០២៧ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ៤ | ពង្រឹងការអនុវត្ត និងធ្វើបច្ចុប្បន្នភាពនូវបទប្បញ្ញត្តិ និងគតិយុត្ត ពាក់ព័ន្ធ ដើម្បីសម្រួលដល់ប្រតិបត្តិការរបស់ ស.ម.ត.ម.។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ព.ណ.<br>- ក.ក.ប.<br>- ក.អ.ក.<br>- គ.វ.ម.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |
| ៥ | សិក្សា និងកាត់បន្ថយក្របខ័ណ្ឌគតិយុត្ត ដែលមានជាធរមាន (ដូចជា អាជ្ញាបណ្ណ លិខិតអនុញ្ញាត ធ្វើសាមញ្ញកម្មលើការងារអធិការកិច្ច ការងារត្រួតពិនិត្យអនុលោមភាព ជាដើម) មកលើ ស.ម.ត.ម. ចៀសវាងការអនុវត្តត្រួតគ្នានាំឱ្យមានចំណាយថវិកា ពេលវេលាច្រើន ថ្លៃដើមខ្ពស់ និងធានាបានការប្រកួតប្រជែងស្មើភាព។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ព.ណ.<br>- ក.ក.ប.<br>-គ.វ.ម.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |
| ៦ | បង្កើនការផ្សព្វផ្សាយស្ដីពីបទដ្ឋានគតិយុត្តនានារបស់ ស.ម.ត.ម. ដល់ធុរជន។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ព.ណ.<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៧ | រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអភិវឌ្ឍ ស.ម.ត.ម. ដែលរួមបញ្ចូលនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់និយមន័យ និងលក្ខខណ្ឌចាត់ថ្នាក់ ទម្រង់នីតិបុគ្គល យន្តការចាត់ថ្នាក់ របបអាជ្ញាបណ្ណ កញ្ចប់អន្តរាគមន៍ យន្តការចាត់ថ្នាក់ឡើងវិញ និងការចាកចេញពីស្ថានភាពជា ស.ម.ត.ម. និងការបិទសហគ្រាស។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ព.ណ.<br>- ក.ក.ប.<br>- ក.អ.ក.<br>- គ.វ.ម.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |

| ១.២. ការបន្តកែលម្អប្រព័ន្ធផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច | | | |
|---|---|---|---|
| **ល.រ.** | **ផែនការសកម្មភាពគន្លឹះ** | **ក្រសួង ស្ថាប័ន ទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| ១ | រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធចុះបញ្ជីអាជីវកម្ម និងការចាត់ថ្នាក់ សម្រាប់ ស.ម.ត.ម. លើថ្នាលឌីជីថលរួម (Single Portal) ដែលមានលក្ខណៈសាមញ្ញ និងមិនទាមទារព័ត៌មានច្រើន ដោយដាក់បន្ថែមនូវយន្តការចាត់ថ្នាក់ និងទទួលស្គាល់ ស.ម.ត.ម. ជាផ្លូវការក្នុងពេលចុះបញ្ជីតែម្តង។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- អ.ព.ដ.<br>- ក.ព.ណ.<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |
| ២ | ឌីជីថលូបនីយកម្មប្រព័ន្ធសេវាសាធារណៈ ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព អន្តរប្រតិបត្តិការ សន្តិសុខទិន្នន័យ និងការផ្តល់សេវាកាន់តែជិតដល់ប្រជាពលរដ្ឋ និងធុរកិច្ច។ | - អគ្គលេខាធិកាដ្ឋាន គ.ស.ធ.ឌ.<br>- ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ប.ទ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៣ | សិក្សា និងកំណត់យន្តការចាត់ថ្នាក់ឡើងវិញ (Reclassifica_tions) ដែលត្រូវអនុវត្តរៀងរាល់ ៣ ឆ្នាំម្តង សំដៅផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពនូវទំហំ និងស្ថានភាព ស.ម.ត.ម. ទាំងថ្មី ទាំងចាស់ ដែលបានចុះបញ្ជី។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |
| ៤ | រៀបចំយន្តការផ្តល់ទិន្នន័យ និងចែករំលែកព័ត៌មានទំនាក់ទំនងសាធារណៈ ប្រព័ន្ធទទួលបណ្តឹងតវ៉ា និងសេវាប្រឹក្សាយោបល់។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ផ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |
| ៥ | រៀបចំតុសេវាគាំទ្រ (Support Desk) ឬសេវាប្រឹក្សាអនឡាញ សម្រាប់ជួយគាំទ្រ និងសម្រួលនីតិវិធីនាំចេញ នាំចូលដល់ ស.ម.ត.ម.។ | - អ.គ.រ. | ២០២៦-២០២៧ |

## ១.៣. ការពង្រឹងសមត្ថភាពវិស័យសាធារណៈ និងលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| ១ | ពង្រឹងសមាគម/សហព័ន្ធសមាគមតំណាង ស.ម.ត.ម. ទូទាំងប្រទេស ដើម្បីធ្វើជាដៃគូជាមួយវិស័យសាធារណៈ ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធផ្សេងទៀត និងលើកកម្ពស់កិច្ចពិគ្រោះយោបល់រវាង តំណាង ស.ម.ត.ម. ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ព.ណ.<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ២ | ពង្រឹងសមត្ថភាពមន្ត្រីសាធារណៈឱ្យស្របតាមក្របខ័ណ្ឌគោលនយោបាយ និងពង្រឹងអភិបាលកិច្ចសម្រាប់គាំទ្រ ស.ម.ត.ម.។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ព.ណ.<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៣ | រៀបចំយន្តការពង្រឹងសមត្ថភាពដល់ ស.ម.ត.ម. ក្នុងការគ្រប់គ្រងអាជីវកម្ម ប្រកបដោយចីរភាព លើការគ្រប់គ្រងអង្គភាព ចំណេះដឹងហិរញ្ញវត្ថុនិងឌីជីថល និងការយល់ដឹងអំពីបទដ្ឋានគតិយុត្ត និងគោលនយោបាយ។ | - ក.ឧ.វ.ប.ន.<br>- ក.ប.ទ.<br>- ក.ព.ណ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍន៍ | ២០២៦-២០៣០ |
| ៤ | បន្តលើកកម្ពស់សហគ្រិនភាពស្ត្រី និងគាំទ្រដល់ ស.ម.ត.ម. ដឹកនាំដោយស្ត្រីតាមរយៈការពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសហគ្រិនភាពស្ត្រី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅតាមបណ្តាខេត្ត។ | - ក.ឧ.វ.ប.ន.<br>- ក.ក.ន<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍន៍ | ២០២៦-២០៣០ |

## យុទ្ធសាស្ត្រទី២. ការលើកកម្ពស់សមត្ថភាពផលិតកម្ម សេវាកម្ម និងការចាប់យកបច្ចេកវិទ្យា និងនវានុវត្តន៍

### ២.១. ការលើកកម្ពស់សហគ្រិនភាព និងបង្កើនការអភិវឌ្ឍបច្ចេកវិទ្យានិងនវានុវត្តន៍

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| ១ | បង្កើតកម្មវិធីជំនួយបច្ចេកទេស និងបណ្តុះបណ្តាលបុគ្គលិក ស.ម.ត.ម. ផ្តោតលើការផ្ទេរបច្ចេកវិទ្យា និងនវានុវត្តន៍ ការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការគ្រប់គ្រងធុរកិច្ច និងការបង្កើនផលិតភាព និងគុណភាព ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងដល់ ស.ម.ត.ម. នៅក្នុងទីផ្សារជាតិ និងអន្តរជាតិ។ | - ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក.ប.ទ.<br>- ក.ក.ប.<br>- សហគ្រិនខ្មែរ<br>- ម.ធ.ត.<br>- ម.អ.ជ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- វិស័យឯកជន | ២០២៦-២០៣០ |
| ២ | លើកទឹកចិត្តឱ្យ ស.ម.ត.ម. ប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទីផ្សារឌីជីថល បច្ចេកវិទ្យាហិរញ្ញវត្ថុ កម្មវិធីគណនេយ្យ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា (ប.វ.អ.) និងឧបករណ៍បញ្ញាសិប្បនិម្មិត ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងធុរកិច្ច។ | - ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក.ប.ទ.<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៣ | រៀបចំយន្តការជំរុញ និងលើកទឹកចិត្ត ស.ម.ត.ម. ក្នុងការធ្វើឌីជីថលូបនីយកម្មនៃដំណើរការផលិត កែច្នៃ និងសេវាកម្មតាមរយៈការចាប់យកបច្ចេកវិទ្យា និងប្រើប្រាស់សម្ភារឧបករណ៍ទំនើបៗ ដែលជួយបង្កើនផលិតភាព។ | - ក.ឧ.វ.ប.ន.<br>- ក.ប.ទ.<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៤ | ពង្រឹងការការពារកម្មសិទ្ធិបញ្ញា ដើម្បីជំរុញការសិក្សាស្រាវជ្រាវ បង្កើតតក្កកម្មថ្មី និងការប្រកួតប្រជែងប្រកបដោយចីរភាព និងប្រមូលផ្តុំចងក្រងប្រព័ន្ធទិន្នន័យ និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងអំពីកម្មសិទ្ធិបញ្ញានានា។ | - ក.ឧ.វ.ប.ន<br>- ក.ព.ណ.<br>- ក.ស.ក<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ៥ | ជំរុញការផ្សារភ្ជាប់រវាងប្រតិបត្តិករសិល្បៈប្រពៃណី ជាមួយអ្នកវិនិយោគ និងអ្នកច្នៃប្រឌិតដើម្បីលើកកម្ពស់តម្លៃវប្បធម៌លើផលិតផលកម្ពុជា។ | - ក.ឧ.វ.ប.ន.<br>- ក.វ.ស.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៦ | លើកទឹកចិត្តការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) និងគម្រោងច្នៃប្រឌិតតាមរយៈការគាំទ្រធនធានដោយមូលនិធិស្រាវជ្រាវជាតិ។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- ក.វ.ស.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ២.២. ការជំរុញការតភ្ជាប់ខ្សែច្រវាក់តម្លៃសកលរបស់ ស.ម.ត.ម. ជាមួយឧស្សាហកម្មប្រតិគមន៍ (Backward Linkage) និងអនុគមន៍ (Forward Linkage) | | | |
| ១ | សិក្សា និងដាក់ឱ្យអនុវត្តកម្មវិធីជំរុញការតភ្ជាប់រវាង ស.ម.ត.ម. ជាមួយក្រុមហ៊ុនវិនិយោគពីបរទេសបម្រើការនាំចេញ សហគ្រាសធុនធំ និងអ្នកកែច្នៃក្នុងស្រុក តាមរយៈការរៀបចំព្រឹត្តិការណ៍ និងកម្មវិធីផ្គូផ្គងអាជីវកម្មរវាងសហគ្រាសធុនធំ និង ស.ម.ត.ម. កម្មវិធីអភិវឌ្ឍអ្នកផ្គត់ផ្គង់ ការសម្របសម្រួលព័ត៌មាន ការលើកកម្ពស់សមត្ថភាព ការគាំទ្រហិរញ្ញប្បទាន និងការគាំទ្របច្ចេកទេស សំដៅផ្សារភ្ជាប់ច្រវាក់តម្លៃក្នុងស្រុក និងលើកកម្ពស់សមត្ថភាពឧស្សាហកម្មរបស់ ស.ម.ត.ម.។ | - ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក.ស.ហ.វ.<br>- ក.អ.ក.<br>- ក.ស.ក.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |
| ២ | ពង្រឹងគុណភាពផលិតផល ឬសេវា របស់ ស.ម.ត.ម. ឱ្យស្របតាមស្តង់ដា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសធំៗ អ្នកកែច្នៃ និងអ្នកទិញក្នុងខ្សែច្រវាក់តម្លៃ។ | - ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៣ | រៀបចំ និងអនុវត្តកម្មវិធីទិញពីក្នុងស្រុក (Local Sourcing) និងកិច្ចសន្យាផ្គត់ផ្គង់ (Subcontracting) ជាមួយឧស្សាហកម្មដែលស្ថិតនៅក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស ដើម្បីបង្កើនការប្រើប្រាស់ធាតុចូល និងសេវាកម្មក្នុងស្រុក។ | - ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក.ស.ហ.វ.<br>- ក.អ.ក.<br>- ក.ស.ក.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| ៤ | ពង្រឹងយន្តការ និងផ្តល់ជំនួយហិរញ្ញវត្ថុតាម SME Linkage Fund ឬជំនួយផ្គូផ្គង (Matching Grant) តាមរយៈសហគ្រិនខ្មែរ ដើម្បីកែលម្អសមត្ថភាពផលិត និងគុណភាព។ | - ក.ឧ.វ.ប.ន.<br>- សហគ្រិនខ្មែរ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៥ | ជំរុញការផ្សារភ្ជាប់រវាងក្រុមផលិតកម្មកសិកម្ម ជាមួយនឹងអ្នកកែច្នៃ អ្នកប្រមូលទិញ អ្នកចែកចាយ និងទីផ្សារ សំដៅគាំទ្រប្រតិបត្តិការផលិតរបស់ ស.ម.ត.ម.។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ក.<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| **២.៣. ការជំរុញអនុវត្តន៍ផលិតកម្មនិងសេវាកម្មបៃតង និងសេដ្ឋកិច្ចចក្រា** | | | |
| ១ | លើកទឹកចិត្តឱ្យ ស.ម.ត.ម. អនុវត្តកម្មវិធីផលិតកម្ម និងសេវាកម្មបៃតង ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានធម្មជាតិ និងថាមពល កាត់បន្ថយការបំពុលបរិស្ថាន និងគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទយ៉ាងមានប្រសិទ្ធភាព។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ក.<br>- ក.ស.ហ.វ.<br>- ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ២ | លើកទឹកចិត្តឱ្យ ស.ម.ត.ម. ផលិតតាមគោលការណ៍សេដ្ឋកិច្ចចក្រា ដើម្បីចម្រាញ់ និងកែច្នៃសំណល់ឧស្សាហកម្មឱ្យក្លាយជាផលិតផលថ្មី ដែលអាចបង្កើនតម្លៃបន្ថែម។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ក.<br>- ក.ស.ហ.វ.<br>- ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៣ | លើកទឹកចិត្តឱ្យ ស.ម.ត.ម. ប្រើប្រាស់ស្លាកសញ្ញាបៃតងសម្រាប់ផលិតផលដែលគោរពតាមស្តង់ដា សុវត្ថិភាពបរិស្ថាន និងផលិតតាមគោលការណ៍ចីរភាព ដើម្បីលើកកម្ពស់ភាពទុកចិត្តរបស់ទីផ្សារ និងសមត្ថភាពប្រកួតប្រជែងក្នុងស្រុក និងអន្តរជាតិ។ | - ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក.ស.ហ.វ.<br>- ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ៤ | ផ្ដល់ការលើកទឹកចិត្តចំពោះ ស.ម.ត.ម. ដែលអនុវត្តមេត្រីភាពបរិស្ថានបានជោគជ័យនៅក្នុងអាជីវកម្មរបស់ខ្លួន។ | - ក.ឧ.វ.ប.ន.<br>- ក.ប.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| **យុទ្ធសាស្ត្រទី៣. ការបង្កើនសមត្ថភាពប្រកួតប្រជែង ក្នុងទីផ្សារជាតិ និងអន្តរជាតិ** | | | |
| **៣.១. ការជំរុញនិងលើកកម្ពស់ផលិតភាព** | | | |
| ១ | ជំរុញការអនុវត្តកម្មវិធីជំរុញផលិតកម្មក្នុងស្រុក សម្រាប់ជំនួសការនាំចូល លើមុខទំនិញយុទ្ធសាស្ត្រដែលមានសក្ដានុពល និងផ្ដល់ការគាំទ្រទាំងលើទិដ្ឋភាពហិរញ្ញវត្ថុ មិនមែនហិរញ្ញវត្ថុ បច្ចេកទេស និងការគាំទ្រអនុលោមភាព។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |
| ២ | ជំរុញអនុវត្តឧបករណ៍ផលិតភាព ដូចជា វិធីសាស្ត្រស៥ (5S) រង្វង់ត្រួតពិនិត្យគុណភាព (Quality Control Circle) ខាយហ្សិន (Kaizen) ប្រព័ន្ធលីន (Lean) ផលិតកម្មស្អាត (Cleaner Production) និងផលិតភាពភាពបៃតង (Green Productivity) និងការគ្រប់គ្រងគុណភាពសរុប (Total Quality Management)។ | - ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៣ | ជំរុញការប្រែក្លាយ ស.ម.ត.ម. បែបគ្រួសារ ទៅជា ស.ម.ត.ម. បែបឧស្សាហកម្ម និងការគាំទ្រជំនួយហិរញ្ញវត្ថុ តាមរយៈមូលនិធិលើកកម្ពស់ផលិតភាព ឬកម្មវិធីជំនួយផ្សេងៗ ដើម្បីផ្ទេរបច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងខ្សែប្រវាក់ផលិតកម្ម។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ម.ធ.ជ.<br>- ធ.ស.ក.<br>- ធ.អ.ជ.<br>- សហគ្រិនខ្មែរ<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៤ | បង្កើតសន្ទស្សន៍ផលិតភាពមធ្យមសម្រាប់ធ្វើជាមូលដ្ឋាន ក្នុងការវាស់វែង និងឆ្លុះបញ្ចាំងស្ថានភាព សេដ្ឋកិច្ច ការគ្រប់គ្រង និងកម្រិតផលិតភាពនៃ ស.ម.ត.ម. ដើម្បីធ្វើការប្រៀបធៀបសន្ទស្សន៍នេះជាមួយផលិតភាពអន្តរជាតិ។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |

| ៣.២. ការលើកកម្ពស់គុណភាព និងស្តង់ដា | | | |
|---|---|---|---|
| **ល.រ.** | **ផែនការសកម្មភាពគន្លឹះ** | **ក្រសួង ស្ថាប័ន ទទួលបន្ទុក** | **ក្របខ័ណ្ឌ ពេលវេលា** |
| ១ | សិក្សា រៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីជំរុញការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមក្នុង វិស័យអាទិភាព ដោយផ្តោតលើមុខទំនិញដែលមានសក្តានុពលក្នុងការនាំចេញ និងមានឧត្តមភាពប្រកួតប្រជែង តាមរយៈការគាំទ្រលើទិដ្ឋភាពហិរញ្ញប្បទាន បច្ចេកទេស ទីផ្សារ និងបទដ្ឋានគតិយុត្ត។ | - ក.ស.ហ.វ.<br>- ក.ព.ណ.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |
| ២ | ពង្រឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ (NQI) ដោយកសាង និងវិនិយោគបន្ថែមលើការបង្កើត និងលើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលមាត្រាសាស្ត្រ ការលើកកម្ពស់លទ្ធផលតេស្តនិងវិភាគ អធិការកិច្ច និងវិញ្ញាបនបត្រផលិតផលរបស់កម្ពុជា ឱ្យស្របតាមស្តង់ដាអន្តរជាតិ តាមរយៈការបង្កើនការគាំទ្រផ្នែកបច្ចេកទេស ការបណ្តុះបណ្តាលធនធានមនុស្សនៃមន្ទីរពិសោធន៍តេស្ត និងអ្នកប្រឹក្សាឯកទេសដល់ ស.ម.ត.ម. ដើម្បីទទួលបានវិញ្ញាបនបត្រអន្តរជាតិ ដូចជា ISO, HACCP, GMP និង Eco-label ជាដើម។ | - ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- ក.ស.ក.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |
| ៣ | ពង្រឹងសមត្ថភាព ស.ម.ត.ម. លើការគ្រប់គ្រងគុណភាព ការរចនាផលិតផល និងនវានុវត្តន៍សំបកវេចខ្ចប់។ | -ក.ឧ.វ.ប.ន.<br>-ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |
| ៤ | កសាងម៉ាក «Made in Cambodia» ដោយផ្តោតលើការបង្កើនគុណភាព សោភ័ណភាពផលិតផល កសាងទំនុកចិត្ត និងទាក់ទាញអ្នកប្រើប្រាស់ក្នុងស្រុក និងអន្តរជាតិ ព្រមទាំងលើកទឹកចិត្តឱ្យ ស.ម.ត.ម. ប្រើប្រាស់ស្លាកសញ្ញាបញ្ជាក់ប្រភពផលិតកម្ម ដូចជា "Sourced in Cambodia" "Packaged in Cambodia" "Made in Cambodia" និង "Product of Cambodia" សម្រាប់ផលិតផលដែលបានផលិត ផ្គុំ ដំឡើង កែច្នៃ បំលែង ឬដំណើរការនៅក្នុងកម្ពុជា និងគោរពតាមស្តង់ដាគុណភាព និងសុវត្ថិភាព។ | - ក.ព.ណ.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ៥ | ផ្សព្វផ្សាយ និងសហការផ្នែកទីផ្សារ ពង្រីកទីផ្សារ និងអភិវឌ្ឍស្តង់ដាថ្មីៗ សម្រាប់ការនាំចេញ តាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាក្នុងការធ្វើទំនើបកម្មខ្សែច្រវាក់ផលិតកម្ម។ | - ក.ព.ណ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៦ | ជំរុញការអនុវត្តស្តង់ដា ការអនុវត្តកសិកម្មល្អ (GAP) ការអនុវត្តអនាម័យសត្វល្អ (GAHP) និងការអនុវត្តវារីវប្បកម្មល្អ (GAQP) ដើម្បីធានាគុណភាព សុវត្ថិភាព និងភាពប្រកួតប្រជែងនៃផលិតផលកសិកម្ម កសិ-ឧស្សាហកម្ម និងវារីវប្បកម្ម។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ក.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៧ | សម្របសម្រួល និងគាំទ្រការតភ្ជាប់ទីផ្សារក្នុងស្រុកនូវផលិតផល ស.ម.ត.ម. ក្នុងផ្សារទំនើប។ | - ក.ព.ណ.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៨ | ជំរុញ និងផ្តល់ការគាំទ្រ ស.ម.ត.ម. ចូលរួមពិព័រណ៍អន្តរជាតិ ដើម្បីយល់ដឹងពីបច្ចេកវិទ្យាថ្មីៗ តម្រូវការទីផ្សារអន្តរជាតិ ជាពិសេសសម្រាប់សហគ្រិនស្ត្រី និងវិស័យមានសក្តានុពលក្នុងការនាំចេញ។ | - ក.ព.ណ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៩ | កំណត់វិធានការគ្រប់គ្រងទំនិញនាំចូល ទាំងលើទំនិញជាម្ហូបអាហារ មិនមែនម្ហូបអាហារ ឧបករណ៍ និងសម្ភារប្រើប្រាស់ ដោយកំណត់នូវលក្ខខណ្ឌចុះបញ្ជី ច.ប.ផ. ការរាយការណ៍ព័ត៌មានផលិតផល និងវិធីប្រើប្រាស់ និងត្រូវភ្ជាប់នូវឯកសារបញ្ជាក់គុណភាពនិងសុវត្ថិភាពផលិតផល។ | - ក.ឧ.វ.ប.ន.<br>- ក.ព.ណ.<br>- អ.គ.រ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| | **៣.៣. ការពង្រឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្ម** | | |
| ១ | បង្កើនការផ្តល់ព័ត៌មាន និងលើកកម្ពស់ការយល់ដឹងដល់ ស.ម.ត.ម. អំពីនីតិវិធី និងបែបបទនៃការនាំចេញ ឱ្យស្រប តាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ និងអន្តរជាតិ ដល់ ស.ម.ត.ម. តាមរយៈការរៀបចំប្រមូលផ្តុំ និងចងក្រង ឯកសារព័ត៌មាន និងផ្សព្វផ្សាយគ្រប់ប្រភេទ ស្តីពីតម្រូវការ ស្តង់ដា គុណភាពផលិតផល និងលក្ខខណ្ឌនាំចេញរបស់ ប្រទេសហត្ថលេខីអនុស្សរណៈនៃការយោគយល់ និងកិច្ច ព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីបង្កើនការយល់ដឹង និង ការចាប់យកឱកាសទីផ្សារថ្មីៗ។ | - ក.ព.ណ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ២ | សិក្សា និងរៀបចំយន្តការផ្តល់ការបញ្ជាក់ប្រភពដើមនៃទំនិញ (Traceability) លើផលិតផលសម្រាប់នាំចេញ ដោយផ្តោត លើផលិតផលដែលមានសក្តានុពលមួយចំនួន ដែលអាច អនុលោមតាមស្តង់ដាបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។ | - ក.ព.ណ.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |
| ៣ | ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទីផ្សារ ឱកាសអាជីវកម្ម និង តម្រូវការខ្សែច្រវាក់តម្លៃក្នុងតំបន់ និងអន្តរជាតិ ដល់ ស.ម.ត.ម. សម្រាប់ផលិតផល កសិផលកែច្នៃ និង សេវាកម្ម។ | - ក.ព.ណ.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| | **យុទ្ធសាស្ត្រទី៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ** | | |
| | **៤.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដល់ ស.ម.ត.ម.** | | |
| ១ | រៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការ អភិវឌ្ឍបណ្តុំសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។ | - ក.ឧ.វ.ប.ន.<br>- ក.អ.ក.<br>- ក.រ.ថ.<br>- ក.ស.ជ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៧ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ២ | ជំរុញការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នៅតាមតំបន់សំខាន់ៗ ផ្តោតលើការផ្តល់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា ផ្លូវ បណ្តាញអគ្គិសនី ទឹកស្អាត ទូរគមនាគមន៍ និងប្រព័ន្ធគ្រប់គ្រងកាកសំណល់ប្រកបដោយសុវត្ថិភាព តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន (PPP) និងទាក់ទាញវិនិយោគឯកជន។ | - ក.ឧ.វ.ប.ន.<br>- ក.អ.ក.<br>- ក.រ.ថ.<br>- ក.ស.ដ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៣ | ពង្រឹងការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពលកកើតឡើងវិញ ក៏ដូចជាជំរុញប្រសិទ្ធភាពថាមពល។ | - ក.រ.ថ.<br>- ក.ឧ.វ.ប.ន. | ២០២៦-២០៣០ |
| ៤ | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្គត់ផ្គង់ ស.ម.ត.ម. ដើម្បីបង្ហាញពីសមត្ថភាពផលិតកម្ម និងសេវាកម្ម។ | - ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០២៧ |
| **៤.២. ការបង្កើនលទ្ធភាពទទួលហិរញ្ញប្បទាន និងឥណទាន** | | | |
| ១ | ជំរុញផលិតផលហិរញ្ញប្បទានដែលមានលក្ខខណ្ឌស្របតាមតម្រូវការរបស់ ស.ម.ត.ម. មានជាអាទិ៍ ហិរញ្ញប្បទានចម្រុះ (Blended Financing) ហិរញ្ញប្បទានតាមខ្សែច្រវាក់ផ្គត់ផ្គង់ (Supply Chain Financing) និងហិរញ្ញប្បទានពាណិជ្ជកម្ម (Trade Finance) និងហិរញ្ញប្បទានតាមរយៈការដាក់ផែនការអាជីវកម្ម ចំណូល និងចំណាយជាដើម ដើម្បីជួយ ស.ម.ត.ម. ក្នុងការបង្កើនទុនបង្វិល និងទុនវិនិយោគ។ | - ក.ស.ហ.វ.<br>- ធ.ជ.ក.<br>- ធ.ស.ក.<br>- ធ.អ.ជ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០២៨ |
| ២ | ជំរុញសេវាគាំទ្រលើសពីហិរញ្ញប្បទាន (Beyond Financing) ដើម្បីបង្កើតតម្លៃបន្ថែមជូនអតិថិជន និងគាំទ្រ ស.ម.ត.ម. ក្នុងការចុះបញ្ជីអាជីវកម្ម ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ និងការផ្តល់ប្រឹក្សាផ្នែកច្បាប់ពាក់ព័ន្ធនឹងការគោរពបទប្បញ្ញត្តិជាធរមាន។ | - ក.ស.ហ.វ.<br>- ធ.ជ.ក.<br>- ស.ធ.ក.<br>- សហគ្រិនខ្មែរ<br>- ម.អ.ជ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ៣ | បន្តពង្រឹងប្រព័ន្ធធានាឥណទានរបស់រាជរដ្ឋាភិបាល តាមរយៈ សាជីវកម្មធានាឥណទានកម្ពុជា ដើម្បីសម្រួលបន្ថែមដល់លទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ ស.ម.ត.ម. ក្នុងការពង្រីកសមត្ថភាពប្រតិបត្តិការ។ | - ក.ស.ហ.វ.<br>- ធ.ជ.ក.<br>- ស.ធ.ក.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៤ | ជំរុញការចូលរួមពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍អន្តរជាតិ ដែលអាចផ្ដល់ជំនួយឥណទាន ប្រាក់បញ្ញើ ឬវិនិយោគតាមវិធីសាស្ត្រសមរម្យ ក្នុងការផ្ដល់ជំនួយឥណទាន បង្កើតមូលនិធិសហហិរញ្ញប្បទានសម្រាប់ ស.ម.ត.ម.។ | - ក.ស.ហ.វ.<br>- ក.ឧ.វ.ប.ន.<br>- ធ.ជ.ក.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍន៍ | ២០២៦-២០៣០ |
| ៥ | រៀបចំកម្មវិធីការចាប់យកឌីជីថលរបស់សហគ្រាស ដូចជាការបណ្ដុះបណ្ដាលអំពី Digital Accounting E-invoicing ទម្រង់របាយការណ៍ហិរញ្ញវត្ថុសាមញ្ញ ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល និងឧបករណ៍គ្រប់គ្រប់ហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យ ស.ម.ត.ម. អាចគ្រប់គ្រងសាច់ប្រាក់ និងធនធានហិរញ្ញវត្ថុបានប្រកបដោយប្រសិទ្ធភាព។ | - ក.ស.ហ.វ.<br>- ធ.ជ.ក.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៦ | ជំរុញការផ្ដល់ឱកាសឱ្យ ស.ម.ត.ម. ដែលមានសមត្ថភាពប្រតិបត្តិការល្អ និងមានការកាន់បញ្ជីគណនេយ្យត្រឹមត្រូវ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ចូលរួមក្នុង SME Board នៃទីផ្សារមូលបត្រកម្ពុជា ដើម្បីរកប្រាក់វិនិយោគបន្ថែម និងបង្កើតភាពជឿជាក់របស់វិនិយោគិន។ | - ក.ស.ហ.វ.<br>- ធ.ជ.ក.<br>- អ.ស.ហ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ដៃគូអភិវឌ្ឍន៍ | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ៧ | ជំរុញឱ្យ ស.ម.ត.ម. ប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុឯកជន ដូចជា Venture Capital Funds ការទទួលបានហិរញ្ញប្បទាន តាមទីផ្សារមូលបត្រ ដើម្បីទាក់ទាញវិនិយោគពីវិស័យឯកជន និងទទួលបានធនធានវិនិយោគរយៈពេលវែង សម្រាប់ពង្រីកសមត្ថភាពផលិត ការច្នៃប្រឌិត និងចូលទៅក្នុងទីផ្សារអន្តរជាតិ។ | - ក.ស.ហ.វ.<br>- ធ.ជ.ក.<br>- អ.ស.ហ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- ដៃគូអភិវឌ្ឍន៍ | ២០២៦-២០៣០ |
| ៨ | ពង្រឹងប្រព័ន្ធជានាឥណទាន ការអភិវឌ្ឍ Fintech និងថ្នាលឥណទានឌីជីថល ដើម្បីសម្រួលដល់ ស.ម.ត.ម. ក្នុងដំណើរការហិរញ្ញវត្ថុនិងឥណទាន។ | - ក.ស.ហ.វ.<br>- ធ.ជ.ក.<br>- ក.ឧ.វ.ប.ន.<br>- ធ.ស.ក.<br>- ធ.អ.ជ.<br>- ស.ធ.ក.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០២៨ |
| ៩ | ផ្តល់អាទិភាពជាក់លាក់ដល់សហគ្រិនវ័យក្មេង និងសហគ្រិនស្ត្រី ឬក្រុមងាយរងគ្រោះ តាមរយៈកម្មវិធីអភិវឌ្ឍសហគ្រិនភាពបណ្តាញសហគ្រិនស្ត្រី និងកម្មវិធី Soft Loan ឬ Matching Grant ដែលមានអត្រាការប្រាក់ទាប និងលក្ខខណ្ឌបង់សងដែលមានភាពបត់បែន ដើម្បីជំរុញការចាប់ផ្តើម ច្នៃប្រឌិតនិងពង្រីកធុរកិច្ចប្រកបដោយចីរភាព។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ក.ន.<br>- ធ.ជ.ក.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ១០ | ពិនិត្យលទ្ធភាពផ្តល់វិភាជន៍កញ្ចប់ថវិកាជូន ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា បន្ថែមទៀត ដើម្បីបង្កលក្ខណៈងាយស្រួលដល់សហគ្រាសក្នុងស្រុក ក្នុងការទទួលបានកម្ចី ក្នុងទំហំសមស្រប និងសម្រាប់រយៈពេលវែងជាងមុន។ | - ក.ស.ហ.វ.<br>- ធ.ស.ក.<br>- ធ.អ.ជ. | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| | ៤.៣. ការជំរុញហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់គាំទ្រដល់ ស.ម.ត.ម. | | |
| ១ | រៀបចំវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគុណភាព ការកែច្នៃប្រកបដោយនវានុវត្តន៍ និងការវេចខ្ចប់សម្រាប់ ស.ម.ត.ម.។ | - ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ<br>- វិស័យឯកជន | ២០២៦-២០៣០ |
| ២ | ជំរុញការបណ្តុះបណ្តាលដល់ ស.ម.ត.ម. លើជំនាញបច្ចេកទេស ការគ្រប់គ្រងគុណភាព ជំនាញឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំនាញបៃតង និងបច្ចេកវិទ្យាបៃតង ដោយប្រើប្រាស់យន្តការដែលមានស្រាប់ រួមមាន មូលនិធិអភិវឌ្ឍន៍ជំនាញ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងសហគ្រិនខ្មែរ។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០២៨ |
| ៣ | បង្កើតមជ្ឈមណ្ឌលជាតិភ្ញាស់ ស.ម.ត.ម. (MSME Incubation Center)។ | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៧-២០៣០ |
| ៤ | សិក្សា និងរៀបចំយន្តការសម្រួលដល់ ស.ម.ត.ម. ចូលរួមផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ដល់ស្ថាប័នសាធារណៈ តាមរយៈការផ្តល់កូតាទិញរបស់រដ្ឋសម្រាប់ ស.ម.ត.ម.។ | - ក.ព.ណ.<br>- ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៥ | ជំរុញការអភិវឌ្ឍជំនាញ និងសមត្ថភាពកម្លាំងពលកម្ម តាមរយៈការបង្កើនជំនាញ (Upskilling) ការផ្លាស់ប្តូរជំនាញ (Reskilling) ការរៀនសូត្រពេញមួយជីវិត ការបណ្តុះបណ្តាលជំនាញគ្រប់កម្រិតសម្រាប់ម្ចាស់សហគ្រាស និងកម្មករនិយោជិត ព្រមទាំងការពង្រីកការវាយតម្លៃ និងការទទួលស្គាល់ជំនាញ តាមរយៈប្រព័ន្ធផ្តល់វិញ្ញាបនបត្រ និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សាដែលមានពីមុន (Recognition of Prior Learning – RPL)។ | - ក.ក.ប.<br>- ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ម.អ.ជ.<br>- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ២០២៦-២០៣០ |

| ល.រ. | ផែនការសកម្មភាពគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| ៦ | ពង្រឹងភាពជាដៃគូរវាង ស.ម.ត.ម. និងគ្រឹះស្ថាន អ.ប.វ. តាមរយៈការបណ្តុះបណ្តាលនៅកន្លែងការងារ (Work-based Learning) ការហ្វឹកហ្វឺនកូនជាង ការហាត់ការ និងការបណ្តុះបណ្តាលតាមប្រព័ន្ធឆ្លាស់ (Dual Training) ដើម្បីធានាថាកម្មវិធីបណ្តុះបណ្តាល ឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ទីផ្សារការងារ និងតម្រូវការរបស់សហគ្រាស។ | - ក.ក.ប.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៧ | ពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារការងារ និងការព្យាករតម្រូវការជំនាញ តាមរយៈការពង្រឹងយន្តការប្រមូល ការវិភាគ និងផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារការងារ ទន្ទឹមនឹងការអភិវឌ្ឍយន្តការព្យាករតម្រូវការជំនាញ និងមុខរបរអាទិភាពសម្រាប់ ស.ម.ត.ម. ដើម្បីជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញប្រកបដោយប្រសិទ្ធភាពខ្ពស់។ | - ក.ក.ប.<br>- ក.ឧ.វ.ប.ន.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |
| ៨ | ពង្រីកវិសាលភាពគ្របដណ្តប់នៃរបបសន្តិសុខសង្គម និងលើកកម្ពស់លក្ខខណ្ឌការងារសម្រាប់ ស.ម.ត.ម. សំដៅបង្កើនភាពធន់របស់សហគ្រាស ពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងទំនាក់ទំនងវិជ្ជាជីវៈ រក្សាកម្លាំងពលកម្ម លើកកម្ពស់សុខុមាលភាពកម្មករនិយោជិត បង្កើនផលិតភាពកាត់បន្ថយអត្រាផ្លាស់ប្តូរការងារ ឬឈប់ពីការងារ និងជំរុញការធ្វើអន្តរកាលចូលក្នុងប្រព័ន្ធ។ | - ក.ក.ប.<br>- ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៦-២០៣០ |